ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ថវិកាសង្ខេប
## ឆ្នាំ ២០២១



# BUDGET IN BRIEF
## FISCAL YEAR 2021

នាយកដ្ឋានថវិកានីយកម្ម
អគ្គនាយកដ្ឋានថវិកា

# មាតិកា


**ជំពូក ១ សេចក្ដីផ្ដើម ........ ៥**

១.១. បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០២១ ........ ៦

១.២. បញ្ហាប្រឈម និង ហានិភ័យ........ ៨

១.៣. អភិក្រម និងគោលការណ៍នៃការរៀបចំថវិកាឆ្នាំ២០២១ ........ ៩

**ជំពូក ២ ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២១........ ១១**

២.១. សូចនាករសេដ្ឋកិច្ច ........ ១២

២.២. កំណើនតាមវិស័យសំខាន់ៗ ........ ១៣

**ជំពូក ៣ ក្របខណ្ឌថវិកាឆ្នាំ ២០២១ ........ ១៧**

៣.១. ស្ថានភាពចំណូលថវិការដ្ឋ........ ១៩

៣.២. ស្ថានភាពចំណាយថវិការដ្ឋ........ ២១

៣.៣. ថវិកាកម្មវិធីនៃក្រសួង ស្ថាប័ន........ ២៨

៣.៤. ការកំណត់ពិតាននៃការខ្ចីសម្រាប់ឆ្នាំ ២០២១........ ៤៩

៣.៥. គម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ........ ៥១

៣.៦. ស្ថានភាពបំណុល........ ៥៣

**ជំពូក ៤ បទប្បញ្ញត្តិស្ដីពីពន្ធដារ ........ ៥៥**

**ជំពូក ៥ សេចក្ដីសន្និដ្ឋាន........ ៥៧**

**ជំពូក ៦ តារាងឧបសម្ព័ន្ធ........ ៥៩**

៦.១. ចំណាយថវិកាចរន្តរបស់ក្រសួង ស្ថាប័ន តាមកម្មវិធីអនុកម្មវិធី........ ៦០

៦.២. ចំណាយថវិកាសរុបរបស់ក្រសួង ស្ថាប័ន ........ ៨៧

# ជំពូក

# ១

## សេចក្ដីផ្ដើម

## ១.១. បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០២១

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ត្រូវបានរៀបចំឡើង នៅក្នុងខណៈដែលប្រទេសជាតិកំពុងស្ថិតនៅក្នុងស្ថានភាពលំបាកនៃវិបត្តិជំងឺកូវីដ-១៩ ហើយជំនន់ទឹកភ្លៀងនាពេលថ្មីៗកន្លងមកនេះ ក៏បានបង្កើនន្ធូវសម្ពាធនៃតម្រូវការចំណាយថវិកានៅឆ្នាំ ២០២១ ខាងមុខ សម្រាប់គោលដៅនៃការស្តារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផលិតកម្មកសិកម្ម ដែលបាន និង កំពុងទទួលរងការខូចខាត ។

ជាក់ស្តែង, ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ ដ៏កាចសាហាវ បាន និង កំពុងបន្តនាំមកនូវផលប៉ះពាល់អវិជ្ជមាន, បញ្ហាប្រឈម និង ហានិភ័យជាច្រើន ដែលមិនធ្លាប់មានពីមុនមកចំពោះតំបន់ និង ពិភពលោកទាំងមូល ដោយគ្មានការលើកលែងចំពោះប្រទេសណាមួយឡើយ, ពិសេស គឺបានធ្វើឱ្យមនុស្សរាប់លាននាក់បាត់បង់ការងារ, ធ្លាក់ចុះនូវប្រាក់ចំណូល, ហើយប្រជាជនមួយចំនួនធំនៅលើពិភពលោក ត្រូវធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញ។ កម្ពុជាក៏មិនអាចគេចរួចពីវិបាកអាក្រក់ទាំងនេះដែរ។ ការរាតត្បាតនៃជំងឺកូវីដ-១៩ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សមិទ្ធផលសង្គម-សេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបាននាពេលកន្លងមកដោយលំបាកប៉ុណ្ណោះទេ, តែថែមទាំងអាចទាញបង្អន់ល្បឿននៃកិច្ចដំណើរការអភិវឌ្ឍន៍ឈានឡើងរបស់កម្ពុជា ពិសេសអាចនឹងពន្យារពេលនៃការឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជា ក្នុងការប្រែក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ ២០៥០ ផងដែរ។ យ៉ាងណាក៏ដោយ, មកដល់ពេលនេះ, ទោះបីកម្ពុជាជាប្រទេសតូច ហើយធនធានក៏នៅមានកម្រិតក្តី, ក្រោមការដឹកនាំដ៏ប៉ិនប្រសព្វ, ឈ្លាសវៃ និង ម៉ឺងម៉ាត់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខរាជរដ្ឋាភិបាលមានសមត្ថភាព និង លទ្ធភាព អាចគ្រប់គ្រងសភាពការណ៍វិបត្តិនៃជំងឺកូវីដ-១៩ បានល្អប្រសើរដោយផ្អែកលើមូលដ្ឋានគ្រឹះរឹងមាំនៃសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ដែលយើងខិតខំកសាងបាននៅក្នុងរយៈពេលជាង ២ ទសវត្សរ៍កន្លងមក, ជាពិសេស ក្នុងរយៈពេល ៧ ឆ្នាំចុងក្រោយ, ព្រមជាមួយនឹងការចូលរួមយ៉ាងសកម្មរបស់គ្រប់តួអង្គពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ផ្តវការ, វិស័យឯកជន និង អង្គការសង្គមស៊ីវិលផងដែរ។

មួយវិញទៀត, ថវិកាឆ្នាំ ២០២១ ក៏ជាថវិកានៃឆ្នាំពាក់កណ្តាលអាណត្តិ ដើម្បីបម្រើឱ្យសំណួមពរនៃការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ដែលត្រូវបានកំណត់នៅក្នុង កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា និង យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៤, នៅលើ

មាគ៌ានៃការកែទម្រង់ស៊ីជម្រៅ និង ការជំរុញការអភិវឌ្ឍ ដោយឈរលើ មូលដ្ឋាននៃសមិទ្ធផលជាច្រើនដែលសម្រេចបានកន្លងមក, ទាំងខាងនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សង្គម, និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, ពិសេសគឺ សន្តិភាព និង ស្ថិរភាពនយោបាយដ៏រឹងមាំ ជាប់មិនដាច់ ដែលជាមូលដ្ឋានគ្រឹះដ៏ចម្បងបំផុត និង មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍជាតិ និង ភាពសុខក្សេមក្សាន្តរបស់ប្រជាជន ។

លើសពីនេះ ជាមួយនឹងកិច្ចប្រឹងប្រែងតស៊ូជម្នះនឹងវិបត្តិនៃជំងឺកូវីដ-១៩ សំដៅកាត់បន្ថយផលប៉ះពាល់នៃវិបត្តិនេះមកលើសុខភាព ជីវភាពរស់នៅរបស់ប្រជាជន និង សង្គម-សេដ្ឋកិច្ចទាំងមូល រាជរដ្ឋាភិបាលក៏បាន និង កំពុងគិតគូរដើម្បីចេញដាក់ចេញនូវ **“ផែនការស្តារសេដ្ឋកិច្ចឡើងវិញ”** សម្រាប់ឆ្នាំ ២០២១-២០២៣, ដែលជាការត្រៀមខ្លួនសម្រាប់ដំណាក់កាលក្រោយវិបត្តិជំងឺកូវីដ-១៩ (Post Covid-19), ដើម្បីឈានទៅបង្កើតបាននូវភាពធន់ (Resiliency) របស់កម្ពុជាទៅនឹងវិបត្តិសម្រាប់រយៈពេលវែងខាងមុខ, រួមបញ្ចូលនូវវិបត្តិសេដ្ឋកិច្ច, ការប្រែប្រួលអាកាសធាតុ និង ការរាតត្បាតនៃជំងឺឆ្លងនានា ផងដែរ ។ ផែនការស្តារនេះ ត្រូវបានគិតគូរដោយផ្តោតលើសសរទ្រូង ៣ ជាសំខាន់ រួមមាន ៖

(១)- ការដាក់ចេញនូវគោលនយោបាយចម្រុះ ទាំងខាងផ្នែកគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង គោលនយោបាយរូបិយវត្ថុ ដើម្បីធ្វើឱ្យសេដ្ឋកិច្ចត្រឡប់មកស្ថិតនៅលើគន្លងនៃកំណើនឡើងវិញក្នុងគោលដៅ ម្ខាងដើម្បីធានាភាពរស់រាន (survive) និង ម្ខាងទៀតដើម្បីធ្វើឱ្យរស់រវើកឡើងវិញ (Revive) ទាំងខាងផ្នែកជីវភាពរស់នៅរបស់ប្រជាជន ក៏ដូចជាផ្នែកអាជីវកម្ម និង ធុរកិច្ច និង សង្គមទាំងមូល ព្រមជាមួយនឹងការតម្រង់ធនធានទៅលើវិស័យសុខាភិបាល វិស័យកសិកម្ម វិស័យទេសចរណ៍ និង សហគ្រាសធុនតូច និង មធ្យម;

(២)- ការដាក់ចេញវិធានការកែទម្រង់សំខាន់ៗ ពិសេស ផ្នែករចនាសម្ព័ន្ធដែលមានលក្ខណៈបន្ទាន់ ដោយផ្អែកលើមេរៀន និង បទពិសោធន៍ដែលកើតចេញពីវិបត្តិ, ដើម្បីប្រែក្លាយវិបត្តិនេះទៅជាកាលានុវត្តភាព សម្រាប់បង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ក៏ដូចជាដើម្បីកសាងនូវមូលដ្ឋានគ្រឹះសម្រាប់ឈានទៅសម្រេចភាពធន់ (Resiliency) របស់កម្ពុជា;

(៣)-ការបង្កើនការវិនិយោគសាធារណៈលើវិស័យគន្លឹះៗ ដែលនឹងធានាឱ្យមានភាពធន់ (Resiliency) ប្រកបដោយបរិយាប័ន្ន និង ចីរភាព, រួមទាំងចីរភាពផ្នែកបរិស្ថាន និង ភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុផង សម្រាប់រយៈពេលវែង តាមរយៈការផ្ដល់អាទិភាព ទៅលើ÷ ការពង្រឹងរដ្ឋបាលសាធារណៈ, ការពង្រឹងការអភិវឌ្ឍធនធានមនុស្ស, ការកសាងហេដ្ឋារចនាសម្ព័ន្ធគន្លឹះៗ ទាំងរូបវន្ត និង ឌីជីថល, ការពង្រឹងប្រព័ន្ធគាំពារសង្គម, ការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង វិស័យហិរញ្ញវត្ថុ ព្រមទាំងការពង្រឹងប្រព័ន្ធសុខាភិបាល ជាដើម។

## ១.២. បញ្ហាប្រឈម និង ហានិភ័យ

សម្រាប់ឆ្នាំ ២០២១ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថា នឹងសម្រេចបានកំណើនក្នុងរង្វង់ ៣,៥% ក្នុងបរិបទនៃការកើនឡើងនូវបញ្ហាប្រឈម និងហានិភ័យទាំងក្នុង និងក្រៅប្រទេស ដែលបាន និងកំពុងបង្កការគំរាមមកលើចីរភាព និងនិរន្តរភាពនៃការអភិវឌ្ឍកម្ពុជា ដូចជា÷



## ១.៣. អភិក្រម និងគោលការណ៍នៃការរៀបចំថវិកាឆ្នាំ ២០២១

ថវិកាឆ្នាំ ២០២១ ត្រូវបានរៀបចំឡើងដោយផ្អែកលើ **អភិក្រមគ្រឹះជាយុទ្ធសាស្ត្រ** និង **គោលការណ៍បច្ចេកទេស**សំខាន់ៗ ដូចខាងក្រោម÷



# ជំពូក

# ២

## ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២១

## ២.១. សូចនាករសេដ្ឋកិច្ច

តាមការព្យាករណ៍ សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០២១ ត្រូវបានព្យាករថានឹងងើបឡើងវិញ ហើយរំពឹងថានឹងសម្រេចបានកំណើនក្នុងរង្វង់ **៣,៥%** ដែលធ្វើឱ្យ ផសស ថ្លៃបច្ចុប្បន្ន ស្ថិតក្នុងរង្វង់ **១១៧ ៩៣៩** ប៊ីលានរៀល, សមមូលនឹងប្រមាណ **២៩ ០១៣** លានដុល្លារអាមេរិក, ស្របពេលដែល ផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ **១ ៧៧១** ដុល្លារអាមេរិក បើប្រៀបធៀបនឹង **១ ៦៨៣** ដុល្លារអាមេរិក ក្នុងឆ្នាំ ២០២០។ ចំណែកឯ**អត្រាប្តូរប្រាក់រៀល** គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់ **៤ ០៦៥** រៀល ក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ ២០២១។ **ឱនភាពគណនីចរន្ត**(រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងរួមតូចបន្តិចមកត្រឹម**១៧,៣%** នៃ ផសស ដោយសារការរំពឹងនៃការងើបឡើងវិញសន្សឹមៗនូវការនាំចេញ និងវិស័យទេសចរណ៍។ **ទុនបម្រុងអន្តរជាតិសរុប** ត្រូវបានរំពឹងថានឹងកើនឡើងដល់ **១៦ ៩៨១** លានដុល្លារអាមេរិក និងធានាការនាំចូលបាន ៨,០ ខែ ដោយហេតុថាការនាំចូលរបស់កម្ពុជាក៏នឹងងើបឡើងបន្តិចវិញ។

| សូចនាករសេដ្ឋកិច្ច | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|
| | អនុវត្ត | ប៉ាន់ស្មាន | ព្យាករណ៍ |
| ផសស តាមថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | ១១០ ០១៤ | ១១០ ៦៥៣ | ១១៧ ៩៣៩ |
| កំណើនពិតនៃ ផសស (%) | ៧,១% | -១,៩% | ៣,៥% |
| ផសស សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | ១ ៧០០ | ១ ៦៨៣ | ១ ៧៧១ |
| អតិផរណា (ជាមធ្យមប្រចាំឆ្នាំ) | ១,៨% | ២,៨% | ៣,១% |
| អត្រាប្តូរប្រាក់ (ដុល្លារអាមេរិក/រៀល) | ៤ ០៥៥ | ៤ ០៦៥ | ៤ ០៦៥ |
| សមតុល្យគណនីចរន្ត (% នៃ ផសស) | -១៥,៥% | -១៧,៦% | -១៧,៣% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | ១៨ ៧៦៣ | ១៦ ៩៣៧ | ១៦ ៩៨១ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ៨,៨ | ៨,៥ | ៨,០ |




- អត្រាអតិផរណាត្រូវបានប៉ាន់ស្មានថាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងអត្រា ៣,១% ក្នុងឆ្នាំ២០២១ ដោយសារការរំពឹងទុកការកើនឡើងថ្លៃប្រេងលើទីផ្សារអន្តរជាតិ បន្ទាប់ពីការធ្លាក់ចុះយ៉ាងគំហុកក្នុងឆ្នាំ ២០២០។

- អត្រាប្តូរប្រាក់រៀល ត្រូវបានប៉ាន់ស្មានថានឹងនៅតែបន្តមានស្ថិរភាពក្នុងរង្វង់ ៤ ០៦៥រៀលក្នុងមួយដុល្លារអាមេរិកក្នុងឆ្នាំ ២០២១ ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជំនឿទុកចិត្ត ពីសំណាក់សាធារណជនលើការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ។

## ២.២. កំណើនតាមវិស័យសំខាន់ៗ

តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ ២០២១ ត្រូវបានទ្រទ្រង់ដោយ÷

## (ទី១)

### វិស័យ ឧស្សាហកម្ម

ត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រាកំណើន ៤,១% ក្នុងឆ្នាំ ២០២១ ពីកំណើនអវិជ្ជមានក្នុងអត្រា-២,២% ក្នុងឆ្នាំ ២០២០ ដោយសារការរំពឹងទុកនូវការងើបឡើងវិញក្នុងកម្រិតទាបនៃអនុវិស័យកាត់ដេរ និងអនុវិស័យសំណង់ ខណៈដែលអនុ-វិស័យកម្មន្តសាលមិនមែនកាត់ដេរត្រូវបានរំពឹងថានៅរក្សាបានកំណើនល្អប្រសើរ។ អនុវិស័យកាត់ដេរ ត្រូវបានរំពឹងថានឹងកើនឡើងក្នុងកម្រិតទាប ដោយសារការរំពឹងទុកពីការងើបឡើងវិញយឺតនៃតម្រូវការខាងក្រៅ។ អនុវិស័យនេះ ក៏ត្រូវប្រឈមនឹងការប្រកួតប្រជែងកាន់តែខ្លាំងក្នុងការដណ្ដើមយកទីផ្សារផងដែរ។ ស្របគ្នានេះ អនុវិស័យសំណង់ក៏ត្រូវបានរំពឹងថានឹងងើបឡើងវិញក្នុងអត្រាកំណើនទាប ដោយសារការកើនឡើងវិញយឺតនៃលំហូរទុនវិនិយោគ ជាពិសេស ពីប្រទេសចិន និងតម្រូវការពេលវេលា ដើម្បីស្ដារទំនុកចិត្តរបស់វិនិយោគិនឡើងវិញ។ ដោយឡែក អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ដូចជា ម្ហូបអាហារនិងភេសជ្ជៈ, ឧស្សាហកម្មដំឡើងយានយន្ត, គ្រឿងបង្គុំអេឡិចត្រូនិក, គ្រឿងបន្លាស់, គ្រឿងសង្ហារិម និងស៊ីម៉ង់ត៍ ជាដើម ទាំងសម្រាប់បម្រើឱ្យការនាំចេញ និងតម្រូវការទីផ្សារក្នុងស្រុក ត្រូវបានរំពឹងថានៅរក្សាបានកំណើនល្អប្រសើរ ដោយសារការពង្រីកមូលដ្ឋានផលិតកម្មផលិតផលមិនមែនកាត់ដេរនៃវិនិយោគដែលមានស្រាប់, ទាំងក្នុង និង ក្រៅតំបន់សេដ្ឋកិច្ចពិសេស, ការរំពឹងទុកនៃនិន្នាការផ្លាស់ប្ដូរទីតាំងរបស់រោងចក្រមួយចំនួនមកកម្ពុជាដែលបណ្ដាលមកពីឥទ្ធិពលនៃសង្គ្រាមពាណិជ្ជកម្ម និងការបង្វែរពីច្រវាក់ផលិតកម្មសកលមកជាច្រវាក់ផលិតកម្មក្នុងតំបន់ក្នុងបរិការណ៍នៃវិបត្តិកូវីដ-១៩។

## (ទី២) វិស័យសេវាកម្ម



ត្រូវបានព្យាករថានឹងមានកំណើនក្នុងអត្រាទាប ៣,៦% ក្នុងឆ្នាំ២០២១ បើប្រៀបធៀបនឹងកំណើនអវិជ្ជមានក្នុងអត្រា -៣,0% ក្នុងឆ្នាំ ២០២០ ដោយសារការរំពឹងទុកនៃការងើបឡើងវិញក្នុងកម្រិតទាបនៃសកម្មភាពសេដ្ឋកិច្ច ជាពិសេសក្នុងវិស័យទេសចរណ៍ និងការប្រើប្រាស់ក្នុងស្រុក បន្ទាប់ពីវិបត្តិកូវីដ-១៩។ អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ត្រូវបានរំពឹងថានឹងមានកំណើនវិជ្ជមានឡើងវិញ ប៉ុន្តែស្ថិតក្នុងកម្រិតទាបនៅឡើយ, ទាំងទំហំ និងអត្រាកំណើន, ដោយសារការធ្លាក់ចុះលទ្ធភាពក្នុងការធ្វើដំណើរកម្សាន្ត ហើយអនុវិស័យនេះអាចត្រូវការរយៈពេលពី ២ ទៅ ៣ ឆ្នាំ ដើម្បីអាចងើបទៅរកទំហំដែលធ្លាប់មានមុនពេលមានវិបត្តិ។ លើសពីនេះ, កម្ពុជាអាចប្រឈមនឹងការប្រកួតប្រជែងខ្ពស់ ដោយសារបណ្តាប្រទេសដែលជាគោលដៅទេសចរណ៍ដទៃទៀត សុទ្ធតែមានវិធានការរៀងៗខ្លួនក្នុងការស្រូបយកភ្ញៀវទេសចរបន្ទាប់ពីស្ថានភាពនៃវិបត្តិនេះបានធូរស្រាល។ អនុវិស័យលក់ដុំ-រាយ ត្រូវបានព្យាករថានឹងមានកំណើនងើបឡើងវិញបន្តិច ប៉ុន្តែទាបជាងនិន្នាការធម្មតា ដែលគាំទ្រដោយការងើបឡើងវិញជាបណ្តើរៗនៃសកម្មភាពប្រើប្រាស់ក្នុងស្រុក ដោយឆ្លុះបញ្ចាំងតាមរយៈឥរិយាបថចាយវាយរបស់ប្រជាពលរដ្ឋ រួមផ្សំនឹងការវិលត្រឡប់មកនៃភ្ញៀវទេសចរអន្តរជាតិ បន្តស្ថិតក្នុងកម្រិតទាប។ ទន្ទឹមនេះ, អនុវិស័យដឹកជញ្ជូន និងគមនាគមន៍ ត្រូវបានរំពឹងថានឹងងើបឡើងវិញ បន្ទាប់ពីសកម្មភាពសេដ្ឋកិច្ចត្រឡប់រកភាពប្រក្រតី ហើយនិន្នាការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងការវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធ នឹងបន្តជំរុញឱ្យអនុវិស័យគមនាគមន៍កាន់តែរីកចម្រើនក្នុងរយៈពេលមធ្យម។

## (ទី ៣) វិស័យកសិកម្ម



វិស័យកសិកម្ម ត្រូវបានប៉ាន់ស្មានថាកើនឡើងក្នុងអត្រា ១,៦% ក្នុងឆ្នាំ ២០២១ ពីកំណើន ០,៩% ក្នុងឆ្នាំ ២០២០ ដោយសារការកើនឡើងនៃអនុវិស័យដំណាំ អនុវិស័យចិញ្ចឹមសត្វ និងអនុវិស័យនេសាទ។ អនុវិស័យដំណាំត្រូវបានព្យាករថានឹងសម្រេចបានកំណើនខ្ពស់ជាងឆ្នាំ ២០២០ ដោយសារការរំពឹងទុកនូវកំណើនផលិតកម្មកសិកម្ម ស្របពេលដែលថ្លៃ និងតម្រូវការខាងក្រៅមានការកើនឡើង។ ជាមួយគ្នាផងដែរ អនុវិស័យចិញ្ចឹមសត្វត្រូវបានព្យាករថានឹងបន្តកំណើនវិជ្ជមានគាំទ្រដោយការរំពឹងទុកនូវកំណើនការចិញ្ចឹមសត្វបែបពាណិជ្ជកម្ម ជាពិសេសការចិញ្ចឹមជ្រូកដែលជំរុញដោយភាពល្អប្រសើរនៃថ្លៃសាច់ជ្រូក។ ទន្ទឹមនេះ អនុវិស័យនេសាទ ត្រូវបានព្យាករថានឹងមានកំណើនខ្ពស់ជាងឆ្នាំ ២០២០ បន្តិច ដែលត្រូវបានជំរុញដោយកំណើនល្អនៃអនុវិស័យវារីវប្បកម្ម ។



# ជំពូក

# ៣

## ក្របខណ្ឌថវិកាឆ្នាំ ២០២១

ឈរលើគោលការណ៍ និង ក្នុងគោលបំណងសម្រេចឱ្យបាននូវគោលនយោបាយខាងលើ, ក្របខណ្ឌថវិកាឆ្នាំ ២០២១ ត្រូវបានកំណត់ដូចខាងក្រោម÷

| **សូចនាករថវិកា** | **២០១៩** | | **២០២០** | **២០២១** |
|---|---|---|---|---|
| | **ច្បាប់** | **អនុវត្ត** | **ច្បាប់** | **ច្បាប់** |
| ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ (%ផសស) | ១៩,២៦ | ២៥,២៦ | ២៣,៨០ | ១៨,១៨ |
| *ចំណូលចរន្ត (%ផសស)* | ១៩,០៨ | ២៥,១០ | ២៣,៦៣ | ១៨,០ |
| ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ (%ផសស) | ២៤,៦៩ | ២៦,០៧ | ៣០,១៣ | ២៧,១៤ |
| *ចំណាយចរន្ត (%ផសស)* | ១៦,២៨ | ១៧,០៦ | ១៧,៩១ | ១៥,៩០ |
| អតិរេកចរន្ត (%ផសស) | ២,៨០ | ៨,០៣ | ៥,៧២ | ២,១០ |
| ឱនភាពសរុប (%ផសស) | -៥,៤៣ | -០,៨១ | -៦,៣៣ | -៨,៩៦ |

- <u>ចំណូលក្នុងប្រទេសថវិការដ្ឋ</u> ត្រូវបានគ្រោង ១៨,១៨% នៃ ផសស ស្មើនឹងចំនួន ២១ ៤៤៥ ៥៩២ លានរៀល។
- <u>ចំណាយសរុបថវិការដ្ឋ</u> ត្រូវបានគ្រោង ២៧,១៤% នៃ ផសស ស្មើនឹងចំនួន ៣២ ០០៩ ៧៤២ លានរៀល។
- <u>អតិរេកថវិកាចរន្ត</u> អាចរក្សាបានក្នុងកម្រិតប្រមាណ ២,១០% នៃ ផសស។
- <u>ឱនភាពថវិកាសរុប</u> ស្មើនឹង -៨,៩៦% នៃ ផសស ហើយ ឱនភាពនេះ ត្រូវបានបំពេញបន្ថែមដោយហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ ៤,៦៣% នៃ ផសស, មូលនិធិទ្រទ្រង់ថវិកាប្រមាណ ០,៧៣% នៃ ផសស និងប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលក្នុងទំហំ ៣,៦០% នៃ ផសសស្មើនឹង ៤ ២៤១ ប៊ីលានរៀល ឬ សមមូលនឹង ១ ០៤៣ លានដុល្លារអាមេរិក ដែលត្រូវបានគ្រោងយកមកប្រើប្រាស់សម្រាប់អនុវត្តគោលនយោបាយ និងវិធានការរក្សាលំនឹង ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ព្រមទាំងសម្រាប់ការស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ។




### ចំណាយចរន្តតាមវិស័យ

- រដ្ឋបាលទូទៅ ១ ៨១៥ ៩២១
- ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ ៤ ៧១៥ ៨៦៩
- សង្គមកិច្ច ៦ ៨៧២ ៧៥៦
- សេដ្ឋកិច្ច ១ ៤៥៩ ៧៥៥

### ចំណាយមូលធន

- វិនិយោគសាធារណៈហិរញ្ញប្បទានក្នុងប្រទេស ៦ ៦០៧ ៨៦១
- វិនិយោគសាធារណៈហិរញ្ញប្បទានក្រៅប្រទេស ៥ ៤៦៥ ៦៥០
- ទូទាត់ប្រាក់ខ្ចី ១ ១៨៥ ១៩០

## ៣.១. ស្ថានភាពចំណូលថវិការដ្ឋ

ក្នុងក្របខណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវបង្កើនចំណូលសរុបថវិការដ្ឋ ឬ ចំណូលសរុបថវិកាជាតិ ឱ្យស្មើនឹង ២៧ ៧៦៨ ៧៤២ លានរៀល ក្នុងនោះ ចំណូលចរន្តថ្នាក់ជាតិឱ្យស្មើនឹង១៩ ៧០៥ ៩៨៣ លានរៀល(ដែលរួមមាន ចំណូលសារពើពន្ធ១៧ ៥២០ ០០០ លានរៀល និង ចំណូលមិនមែនសារពើពន្ធ ២ ១៨៥ ៩៨៣ លានរៀល)។ ដោយឡែក សម្រាប់ចំណូលមូលធនថវិការដ្ឋ ត្រូវបានគ្រោងចំនួន ៦ ៥៤៤ ៣៥៣ លានរៀល, ត្រូវជា ៥,៥៥% នៃ ផសស គឺមានកំណើន ០,៧% ធៀបនឹងច្បាប់ឆ្នាំ ២០២០ ក្នុងនោះចំណូលមូលធនដោយហិរញ្ញប្បទានពីក្រៅប្រទេស ស្មើនឹងប្រមាណជិត ២០% នៃចំណាយថវិការដ្ឋសរុបឆ្នាំ ២០២១ ប៉ុណ្ណោះ។


ចំណូល
មូលធនក្នុងប្រទេស
២២១,២០៣
ចំណូល
មូលធនក្រៅប្រទេស
៦,៣២៣,១៥០
ចំណូលចរន្ត
ថវិកាថ្នាក់ក្រោមជាតិ
១,៥១៨,៤០៦
ចំណូលសរុប
ថវិការដ្ឋ
២៧ ៧៦៨ ៧៤២
ចំណូលចរន្តថវិកាថ្នាក់ជាតិ
១៩,៧០៥,៩៨៣


ចំណូលមិនមែនសារពើពន្ធ
១១%
ចំណូលចរន្តថ្នាក់ជាតិ
១៩ ៧០៥ ៩៨៣
លានរៀល
ចំណូលពន្ធដារ
៤១%
ចំណូលគយ និងរដ្ឋាករ
៤៨%


ពន្ធផ្ទាល់
២៥ %
ពន្ធប្រយោល
៧៥ %
ពន្ធលើពាណិជ្ជកម្ម
ក្រៅប្រទេស
១៣ %
ពន្ធក្នុងប្រទេស
៨៧ %

**ចំណូលមូលធន** ត្រូវសម្រេចឱ្យបានចំនួន ៦ ៥៤៤ ៣៥៣ លានរៀល ក្នុងនោះ

- ចំណូលមូលធនក្នុងប្រទេស ២២១ ២០៣ លានរៀល
- ចំណូលមូលធនក្រៅប្រទេស ៦ ៣២៣ ១៥០ លានរៀល




## ៣.២. ស្ថានភាពចំណាយថវិការដ្ឋ

សម្រាប់ឆ្នាំ ២០២១ **ចំណាយសរុបថវិការដ្ឋ** ឬ **ចំណាយសរុបថវិកាជាតិ** ត្រូវបានគ្រោងចំនួន ៣២ ០០៩ ៧៤២ លានរៀល ត្រូវជា ២៧,១៤% នៃ ផសស គឺថយចុះ ៤,០% ធៀបនឹងច្បាប់ឆ្នាំ ២០២០ ដែលក្នុងនោះ(១)-**ចំណាយចរន្តថវិការដ្ឋ**មានចំនួន ១៨ ៧៥១ ០៤១ លានរៀល ត្រូវជា ១៥,៩០% នៃ ផសស គឺថយចុះ ៥,៤% ធៀបនឹងច្បាប់ឆ្នាំ ២០២០ និង ( ២)-**ចំណាយមូលធនថវិការដ្ឋ**មានចំនួន ១៣ ២៥៨ ៧០១ លានរៀល ត្រូវជា ១១,២៤% នៃ ផសស គឺថយចុះ ១,៩% ធៀបនឹងច្បាប់ឆ្នាំ ២០២០។

## ចំណាយចរន្ត

**បន្ទុកបុគ្គលិកសរុប**
**៩ ៣២៦ ៥៨៩ លានរៀល**

ថ្នាក់ជាតិ÷ ៨ ៥៦៥ ៥៧៤ លានរៀល
ថ្នាក់ក្រោមជាតិ÷ ៧៦១ ០១៥ លានរៀល

**ក្រៅបន្ទុកបុគ្គលិកសរុប**
**៩ ៤២៤ ៤៥២ លានរៀល**

ថ្នាក់ជាតិ÷ ៨ ៨៨១ ២៦៧ លានរៀល
ថ្នាក់ក្រោមជាតិ÷ ១ ៦០៣ ៦៣៥ លានរៀល *

***សំគាល់÷ទំហំចំណាយចរន្តក្រៅបន្ទុកបុគ្គលិកថ្នាក់ក្រោមជាតិបានបូកបញ្ចូល នូវឥណទានឧបត្ថម្ភកធនពីថ្នាក់ជាតិចំនួន ១ ០៦០ ៤៥០ លានរៀល។**




## ចំណាយមូលធន

**វិនិយោគសាធារណៈ: ហិរញ្ញប្បទានក្នុងប្រទេសសរុប**
**៦ ៦០៧ ៨៦១ លានរៀល**

ថ្នាក់ជាតិ ÷ ៦ ៣៩៣ ៦៥៥ លានរៀល
ថ្នាក់ក្រោមជាតិ ÷ ២១៤ ២០៦ លានរៀល

**វិនិយោគសាធារណៈ:ហិរញ្ញប្បទានក្រៅប្រទេស**
**៥ ៤៦៥ ៦៥០ លានរៀល**

**ការទូទាត់ប្រាក់ខ្ចី**
**១ ១៨៥ ១៩០ លានរៀល**

## ក. ចំណាយចរន្តថ្នាក់ជាតិ




## ក.១. ចំណាយលើបន្ទុកបុគ្គលិក

ចំណាយលើបន្ទុកបុគ្គលិក ត្រូវបានគ្រោងចំនួន ៨ ៥៦៥ ៥៧៤ លានរៀល មានសមាមាត្រស្មើនឹង ៤៩,១% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា ៧,២៦% នៃ ផសស, មានកំណើន ០,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០។ ចំណាយបន្ទុកបុគ្គលិកនេះ ត្រូវបានគ្រោងដោយរក្សាកម្រិតប្រាក់បៀវត្សអប្បបរមា និងប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងកម្លាំងប្រដាប់អាវុធឆ្នាំ ២០២១ ស្មើនឹងកម្រិតឆ្នាំ ២០២០ ដើម្បីសន្សំថវិកាសម្រាប់ទប់ទល់ការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលបានបង្កនូវផលប៉ះពាល់ដល់សេដ្ឋកិច្ច សុខភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសកម្មករនិយោជិតនៃឧស្សាហកម្មកាត់ដេរ និងវាយនភណ្ឌ កម្មករក្រៅប្រព័ន្ធ ក៏ដូចជាប្រជាជនក្រីក្រ និងជនងាយរងគ្រោះ។ ក៏ប៉ុន្តែ សម្រាប់មន្ត្រីរាជការ, រាជរដ្ឋាភិបាលបន្តធានាបាននូវការបើកផ្តល់បៀវត្សបានទាន់ពេលវេលា គឺ២ដង ក្នុង១ខែ ទន្ទឹមនេះ រាជរដ្ឋាភិបាលមិនបានកាត់ប្រាក់បៀវត្សមន្ត្រីរាជការនោះទេ ផ្ទុយទៅវិញ រាជរដ្ឋាភិបាលនៅមានលទ្ធភាពរក្សាកម្រិតប្រាក់បៀវត្សអប្បបរមា និងប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងកម្លាំងប្រដាប់អាវុធឆ្នាំ២០២១ ស្មើនឹងកម្រិតឆ្នាំ ២០២០។ ក្នុងន័យនេះ បៀវត្សសរុបអប្បបរមាក្នុងឆ្នាំ ២០២១ ត្រូវបានរក្សាក្នុងកម្រិតដូចខាងក្រោម÷

- បៀវត្សមន្ត្រីរាជការស៊ីវិល រក្សាស្មើនឹងប្រមាណ ១ ១៧២ ៥០០ រៀល;
- បៀវត្សគ្រូបង្រៀន និង គ្រូពេទ្យ រក្សាស្មើនឹងប្រមាណ ១ ២៧២ ៥០០ រៀល;
- បៀវត្សនគរបាល (ពលបាលត្រី) រក្សាស្មើនឹងប្រមាណ ១ ២៥៦ ៩៧៧ រៀល (គិតបញ្ចូលរបបអង្គរ);
- បៀវត្សយោធិន(ពលទោ) រក្សាស្មើនឹងប្រមាណ១ ១២៣ ៥០០ រៀល(មិនគិតបញ្ចូលរបបអង្គរ) ហើយបើគិតបញ្ចូលរបបអង្គរត្រូវជាប្រមាណ ១ ១៨១ ៩៧៧ រៀល។

ទន្ទឹមនេះ ថវិកាចំនួន **៥០ ប៊ីលានរៀល** ត្រូវបានគ្រោងសម្រាប់មូលនិធិថែទាំសុខភាពជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តជន និងបានបន្តគ្រោងថវិកាចំនួន **៦ ប៊ីលានរៀល** ដើម្បីទ្រទ្រង់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ នៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល។ ចំពោះប្រាក់សោធននិវត្តន៍ ក៏ត្រូវបានគ្រោងថវិកាចំនួន **៣០ ប៊ីលានរៀល** សម្រាប់ការដំឡើងរបបសោធនប្រចាំខែទាបបំផុតជូនដល់និវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធផងដែរ ក្នុងគោលដៅជួយគាំទ្រដល់ជីវភាពរបស់ពួកគាត់ ក៏ដូចជាសំដៅកាត់បន្ថយគម្លាតរបបសោធនរបស់និវត្តជនរវាងអ្នកទទួលបានសោធនទាប និងអ្នកទទួលបានសោធនខ្ពស់, និងរវាងនិវត្តជនថ្មី និងនិវត្តជនចាស់។

### ក.២. ចំណាយមិនមែនបន្ទុកបុគ្គលិក

ត្រូវបានគ្រោងចំនួន ៨ ៨៨១ ២៦៧ លានរៀល, មានសមាមាត្រស្មើនឹង ៥០,៩០% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,៥៣% នៃ ផសស គឺថយចុះ ៦,៥% ធៀបនឹងច្បាប់ឆ្នាំ២០២០។ការគ្រោងថយចុះនេះ សម្រេចបានជារួម ដោយសារគ្រប់ក្រសួង-ស្ថាប័នទាំងអស់ ជាទូទៅគោរពបាននូវពិតានចំណាយគោលដែលរាជរដ្ឋាភិបាលបានកំណត់ផ្តល់ជូនសម្រាប់ចំណាយមិនមែនបន្ទុកបុគ្គលិកក្នុងកម្រិតថវិកាវិចារណកម្មចំណាយឆ្នាំ ២០២០ ក្នុងក្របខណ្ឌនៃការធ្លាក់ចុះចំណូល និង ក្នុងគោលដៅសន្សំធនធានសម្រាប់បន្តអន្តរាគមន៍ទប់ទល់នឹងផលប៉ះពាល់ពីវិបត្តិកូវីដ-១៩។ កញ្ចប់ថវិកានេះ ត្រូវបានវិភាជដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់តាមវិស័យនីមួយៗ ដូចខាងក្រោម÷

#### <u>វិស័យរដ្ឋបាលទូទៅ</u>

- បន្តគាំទ្រដល់ការលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងចំណូល និងប្រមូលចំណូល-សារពើពន្ធ,
- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ,

- បន្តគាំទ្រកំណែទម្រង់វិស័យដីធ្លី,
- បន្តគាំទ្រ និងពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ ២០១៥-២០២៥,
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ,
- បន្តគាំទ្រដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចការទូត,
- គាំទ្រដល់ការត្រៀមរៀបចំដំណើរការបោះឆ្នោតឃុំ- សង្កាត់ឆ្នាំ ២០២២,
- គាំទ្រដល់ការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចការប្រជុំកំពូល អាស៊ី-អឺរ៉ុប ឆ្នាំ ២០២១ និងការរៀបចំកិច្ចប្រជុំអន្តរជាតិផ្សេងៗ។

## វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

- បន្តគាំទ្រដល់ការពង្រឹងសមត្ថភាពរបស់នគរបាល និងកងកម្លាំងប្រដាប់អាវុធ,
- បន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ,
- បន្តគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ,
- បន្តគាំទ្រកិច្ចដំណើរការរដ្ឋបាល និងអន្តរាគមន៍ផ្សេងៗ,
- បន្តគាំទ្រដល់ដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ,
- បន្តគាំទ្រការអនុវត្តគោលនយោបាយ ភូមិ- ឃុំ មានសុវត្ថិភាព,
- បន្តគាំទ្រដល់ប្រព័ន្ធត្រួតពិនិត្យសន្តិសុខតាមច្រកព្រំដែន និងការផលិតលិខិតឆ្លងដែន,
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ,
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន,
- បន្តគាំទ្រសេវាឥតគិតថ្លៃរបស់គណៈមេធាវីកម្ពុជា។

## វិស័យសង្គមកិច្ច

- **បន្តគាំទ្រការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩,**
- បន្តគាំទ្រដល់ការលើកកម្ពស់គុណភាព និងការទទួលបានសេវាសុខាភិបាល,
- បន្តគាំទ្រដល់ការពង្រឹងគុណភាព និងគាំទ្រសេវាអប់រំ,
- បន្តគាំទ្រដល់ការលើកកម្ពស់វិស័យកីឡាជាតិ,
- បន្តគាំទ្រដល់ការអភិវឌ្ឍន៍ជំនាញ និងវិស័យការងារ,
- បន្តគាំទ្រដល់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ,
- បន្តឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន,
- បន្តឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាតាមបណ្តារាជធានី-ខេត្ត និង មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា,

- បន្តផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពចំពោះជនក្រីក្រ និងចាស់ជរានៅតាមសហគមន៍,
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ,
- បន្តគាំទ្រដល់ការការពារ និងអភិរក្សធនធានធម្មជាតិ,
- បន្តគាំទ្រដល់ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិ,
- បន្តគាំទ្រដល់សុខដុមនីយកម្មសាសនា។

## វិស័យសេដ្ឋកិច្ច

- បន្តគាំទ្រដល់ការលើកកម្ពស់បច្ចេកទេសកសិកម្ម និង សុវត្ថិភាពចំណីអាហារ,
- បន្តគាំទ្រដល់ការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល,
- បន្តគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ,
- បន្តគាំទ្រដល់ការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ,
- បន្តគាំទ្រដល់ការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ,
- ជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍,
- បន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា,
- បន្តគាំទ្រដល់ការជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត,
- បន្តគាំទ្រដល់ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ,
- បន្តគាំទ្រដល់ការអភិវឌ្ឍន៍ប្រព័ន្ធរដ្ឋបាលអេឡិកត្រូនិក,
- បន្តគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម,
- អភិវឌ្ឍន៍ប្រព័ន្ធស្តង់ដា និងមាត្រាសាស្ត្រ។

ព័ត៌មានបន្ថែមសម្រាប់ទំហំចំណាយថវិកាសរុប (ចំណាយចរន្ត និងចំណាយមូលធនក្នុងប្រទេស និងក្រៅប្រទេស) របស់ក្រសួង ស្ថាប័ន មានក្នុងតារាងឧបសម្ព័ន្ធទី ៣៩។

លើសពីនេះ សម្រាប់ឆ្នាំ ២០២១ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកា ឆ្លើយតបនឹងសកម្មភាពគាំពារសង្គមដែលរួមមានជាអាទិ៍ដូចជា÷

- ការបន្តគាំទ្រការថែទាំសុខភាពសម្រាប់កម្មករ÷ បានត្រៀមថវិកាក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់ពង្រីកវិសាលភាពមូលនិធិសមធម៌ ដើម្បីផ្តល់លទ្ធភាពឱ្យកម្មករ (ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ) ដែលមិនទាន់ជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ទទួលបានរបបថែទាំសុខភាពដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ;

- <u>ការបន្តការឧបត្ថម្ភមាតុភាពសម្រាប់កម្មករនិយោជិត÷</u> បានគ្រោងនៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាលសម្រាប់បន្តបើកផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មការិនី នៅក្រោយពេលសម្រាលកូន និងសម្រាកលំហែមាតុភាព;
- <u>ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា÷</u> បន្តផ្តល់ថវិកាសម្រាប់បង្កើន **"មូលនិធិគន្ធបុប្ផាកម្ពុជា"** បន្ថែមលើថវិកាដែលត្រូវផ្តល់ផ្ទាល់ទៅមន្ទីរពេទ្យគន្ធបុប្ផាសម្រាប់ចំណាយប្រតិបត្តិការ **ឆ្នាំ ២០២១**, ដើម្បីធានានិរន្តរភាព គុណភាព និងប្រសិទ្ធភាព របស់មន្ទីរពេទ្យផង និងធានាការផ្តល់សេវាដោយមិនយកថ្លៃជូនដល់កុមារនៃគ្រួសារក្រីក្រផង;
- <u>ការបន្តសកម្មភាពរបស់រាជរដ្ឋាភិបាលក្នុងការចុះសួរសុខទុក្ខកម្មករ-កម្មការិនី</u> តាមបណ្តារោងចក្រសហគ្រាស ដើម្បីស្វែងយល់និងរកដំណោះស្រាយសមស្របជូនកម្មករ-កម្មការិនី ក៏ដូចជាជំរុញគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម;
- <u>កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារតូច÷</u> បានគ្រោងថវិកាសម្រាប់ឧបត្ថម្ភពេលពិនិត្យផ្ទៃពោះ ចំនួន ៤ លើក, ១ លើក ៤ ម៉ឺនរៀល, ពេលសម្រាលកូននៅមណ្ឌលសុខភាព ឬពេទ្យរដ្ឋ ជូន ២០ម៉ឺនរៀល, ឧបត្ថម្ភ ១០ លើកទៀត ១លើក ៤ ម៉ឺនរៀល ពេលទៅទទួលថ្នាំបង្ការ រហូតដល់កុមារអាយុ ២ ឆ្នាំ។

## ខ. ចំណាយមូលធនថ្នាក់ជាតិ

ត្រូវបានគ្រោងចំនួន ១៣ ០៤៤ ៤៩៥ លានរៀល មានសមាមាត្រស្មើនឹង៤២,៨% នៃចំណាយថវិកាថ្នាក់ជាតិសរុប ត្រូវជា១១,០៦% នៃ ផសស, ថយចុះ0,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០ ក្នុងគោលដៅគាំទ្រដល់ការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល (២០២១-២០២៣) ជាពិសេសគឺការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ។ គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ ត្រូវបានគ្រោងចំនួន ៦ ៣៩៣ ៦៥៥ លានរៀល ត្រូវជា ៥,៤២% នៃ ផសស មានកំណើន ៨,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២០ ដោយផ្តោតអាទិភាពទៅលើ÷

- <u>ការបន្តត្រៀមអន្តរាគមន៍ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ មានដូចជា÷</u>
  - កម្មវិធីឧបត្ថម្ភគ្រួសារក្រីក្រ(ក្រ១ និងក្រ២) និងជនងាយរងគ្រោះ ត្រូវបានគ្រោងទឹកប្រាក់ចំនួន ៨២០ ប៊ីលានរៀល សមមូលនឹងប្រមាណ ២០០ លានដុល្លារអាមេរិក
  - កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ ត្រូវបានគ្រោងទឹកប្រាក់ចំនួន ២៣៩ ប៊ីលានរៀល សមមូលនឹងប្រមាណ ៥៩ លានដុល្លារអាមេរិក

- គម្រោងសាច់ប្រាក់ពលកម្ម (Cash for Works) ត្រូវបានគ្រោងទឹកប្រាក់ចំនួន ៦៥០ ប៊ីលានរៀល សមមូលនឹងប្រមាណ ១៦០ លានដុល្លារអាមេរិក សម្រាប់ស្រូបយកកម្លាំងពលកម្មដែលបាត់បង់ការងារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅជនបទ មានដូចជាប្រឡាយដើងក្អែប ស្រះទឹក អណ្តូង និងបង្គន់អនាម័យនៅតាមសាលារៀនជាដើម

- មូលនិធិត្រៀមបម្រុងសម្រាប់គាំទ្រដល់សេដ្ឋកិច្ច/ សហគ្រាសធនតូច និងមធ្យម (SMEs) ចំនួន ១ ០៩៧ ប៊ីលានរៀល សមមូលនឹងប្រមាណ ២៧០ លានដុល្លារអាមេរិក។

- ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន លូ ជាពិសេសការជួសជុលឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលរងផលប៉ះពាល់ពីជំនន់ទឹកភ្លៀង រួមទាំងការកសាងប្រព័ន្ធចម្រោះទឹកកខ្វក់ ប្រព័ន្ធលូ អូរ ប្រឡាយរំដោះទឹកភ្លៀង និងប្រព័ន្ធបង្ហូរទឹកកខ្វក់
- ការកសាង និងជួសជុលផ្លូវចំនួន ៣៨ ខ្សែ ក្នុងទីរួមខេត្តសៀមរាប
- ការបន្តស្តារនិងកសាងប្រព័ន្ធធារាសាស្ត្រ និងលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ
- ការជំរុញផលិតកម្មស្បៀង និងការលើកកម្ពស់ផលិតភាពកសិកម្ម
- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់មួយចំនួនផ្សេងទៀត
- ការពង្រឹកសមត្ថភាពបញ្ជូន និងចែកចាយផ្គត់ផ្គង់អគ្គិសនី។

## ៣.៣. ថវិកាកម្មវិធីនៃក្រសួង ស្ថាប័ន

### ក្រសួងអប់រំ យុវជន និងកីឡា

មានគោលនយោបាយចំនួន២ គឺ÷

- ទី ១ ÷ ធានាឲ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

- ទី ២ ÷ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

៣ ២០៧ ២២០ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១. ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ

២. ការអភិវឌ្ឍឧត្តមសិក្សានិងការស្រាវជ្រាវ

៣. ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

៤. ការអភិវឌ្ឍជំនាញបច្ចេកទេស និងជំនាញទន់សម្រាប់យុវជន

៥. ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១ នៃឧបសម្ព័ន្ធ

## ក្រសួងសុខាភិបាល

មានគោលនយោបាយចំនួន ១ គឺ÷ លើកកម្ពស់លទ្ធផលសុខភាពប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង និង បង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុក្នុងការប្រើប្រាស់សេវាថែទាំសុខភាព។

១ ៧២០ ៦៣៨ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ÷

១. សុខភាពបន្តពូជយុវវ័យ មាតា ទារក កុមារ និងអាហាររូបត្ថម្ភ

២. ប្រយុទ្ធជំងឺឆ្លង

៣. ប្រយុទ្ធជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត

៤. ពង្រឹងប្រព័ន្ធសុខាភិបាល

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២នៃឧបសម្ព័ន្ធ

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

មានគោលនយោបាយចំនួន ១ គឺ ÷ ពង្រឹងប្រព័ន្ធគាំពារ និងផ្តល់សេវាសុខុមាភាពសង្គម ប្រកបដោយ ប្រសិទ្ធភាព និងសមធម៌។

១ ២៨៧ ៦៩៥ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៣ គឺ÷

១. សេវាសុខុមាលភាពសង្គម

២. ការគ្រប់គ្រងរបបសន្តិសុខសង្គម និងសេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ

៣. ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣នៃឧបសម្ព័ន្ធ</u>

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

មានគោលនយោបាយចំនួន ១ គឺ ÷ ការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២៦៤ ៣៥៧ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១. ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

២. ទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

៣. បរិយាកាសមុខរបរ និងការងារកាន់តែទូលំទូលាយ

៤. ការអភិវឌ្ឍរបបសន្តិសុខសង្គម

៥. ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៤នៃឧបសម្ព័ន្ធ</u>

## ក្រសួងបរិស្ថាន

មានគោលនយោបាយចំនួន១ គឺ ÷ កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និង ការគ្រប់គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាព។

៣៥ ៤៩៣
លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១. កិច្ចគាំពារបរិស្ថាន
២. ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន
៣. ការគ្រប់គ្រងការអភិវឌ្ឍដោយចីរភាព
៤. ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានបរិស្ថាន
៥. សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៥នៃឧបសម្ព័ន្ធ</u>

## ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

មានគោលនយោបាយចំនួន ១ គឺ ÷ អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ។

១៦៥ ០៥៦
លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

១. កិច្ចគាំពារបេតិកភណ្ឌវប្បធម៌រូបី
២. ការលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី
៣. ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៦នៃឧបសម្ព័ន្ធ</u>

## ក្រសួងព័ត៌មាន

មានគោលនយោបាយចំនួន ១ គឺ ÷ ការលើកកម្ពស់សេវា ព័ត៌មាន ធានាឱ្យបាននូវសិទ្ធិទទួលបានព័ត៌មានពេញលេញ ទាន់ពេលវេលា និងសុក្រឹត្យ។

៨០ ៥៥៨ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

ការគ្រប់គ្រង និងអភិវឌ្ឍវិស័យព័ត៌មាន

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៧នៃឧបសម្ព័ន្ធ</u>

## ក្រសួងកិច្ចការនារី

មានគោលនយោបាយចំនួន ១ គឺ ÷ ប្រែក្លាយស្ត្រីជាកម្លាំងចលករ ដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ កែប្រែស្ថានភាពសេដ្ឋកិច្ច សង្គម និងនយោបាយរបស់ស្ត្រី ឱ្យមានការប្រែប្រួលល្អប្រសើរជាលំដាប់ ដើម្បីសុភមង្គលគ្រួសារ។

៤៤ ៥៣៨ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ÷

១. កែប្រែស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ស្ត្រី
២. កិច្ចការពារផ្លូវច្បាប់ចំពោះស្ត្រី និងកុមារ
៣. ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយជាតិ និងតាមវិស័យ
៤. ការគ្រប់គ្រង និងការអភិវឌ្ឍស្ថាប័ន

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៨នៃឧបសម្ព័ន្ធ</u>

## ក្រសួងធម្មការ និងសាសនា

មានគោលនយោបាយចំនួន ១ គឺ ÷ លើកកម្ពស់សាសនារបស់រដ្ឋ តម្លៃសីលធម៌សង្គម និងសុខដុមនីយកម្មសាសនា។

៦៦ ២៧០ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

សុខដុមនីយកម្មសាសនានៅកម្ពុជា

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៩នៃឧបសម្ព័ន្ធ</u>

## ក្រសួងទេសចរណ៍

មានគោលនយោបាយចំនួន ១ គឺ ÷ ជំរុញកំណើនទេសចរណ៍និងបង្កើនតម្លៃបន្ថែមតាមរយៈវិស័យទេសចរណ៍នៅកម្ពុជា។

៥៤ ១៧៥ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

១. ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

២. ការអភិវឌ្ឍទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ

៣. សេវាគាំទ្រដំណើរការទូទៅរបស់ស្ថាប័ន

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១០នៃឧបសម្ព័ន្ធ</u>

មានគោលនយោបាយចំនួន ១ គឺ ÷ ការគ្រប់គ្រង អភិវឌ្ឍន៍ និងអភិរក្សធនធានទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់ សមធម៌ និងនិរន្តរភាព។

១៥៨ ៦១៩ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក

២. ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត

៣. ការការពារ និងអភិរក្សធនធានទឹក

៤. ការគ្រប់គ្រងព័ត៌មានស្ដីពីធនធានទឹក និងឧតុនិយម

៥. ការគ្រប់គ្រងរដ្ឋបាល និងសេវាទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១១នៃឧបសម្ព័ន្ធ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

មានគោលនយោបាយចំនួន ១ គឺ ÷ ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព។

២៦១ ៥៥៣ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១. ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច
២. ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ
៣. ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម
៤. ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ
៥. ការបង្កើនប្រសិទ្ធភាព សេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១២នៃឧបសម្ព័ន្ធ

## ក្រសួងពាណិជ្ជកម្ម

មានគោលនយោបាយចំនួន ១ គឺ ÷ ពង្រឹង និង ជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្ម។

១២៣ ៧៤៣ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៣ គឺ÷

១. ការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍន៍វិស័យឯកជន
២. ការត្រួតពិនិត្យគុណភាព សុវត្ថិភាពផលិតផលទំនិញនិងសេវា
៣. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស និងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១៣ នៃឧបសម្ព័ន្ធ

## ក្រសួងរ៉ែ និងថាមពល

មានគោលនយោបាយចំនួន ១ គឺ ÷ ពង្រឹងនិងបង្កើនចំណូលឧស្សាហកម្ម និស្សារណកម្ម ពង្រឹងសមត្ថភាពនិងសន្តិសុខថាមពល រួមទាំង សន្តិសុខ សុវត្ថិភាពវិទ្យុសកម្ម ដោយឈរលើមូលដ្ឋានសេដ្ឋកិច្ច សង្គម និងបរិស្ថាន។

៥៤ ៨០៨ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៤ គឺ÷

១. ការអភិវឌ្ឍធនធានរ៉ែ

២. ការអភិវឌ្ឍវិស័យប្រេងកាត

៣. ការអភិវឌ្ឍ និងការគ្រប់គ្រងវិស័យថាមពល

៤. ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១៤នៃឧបសម្ព័ន្ធ

## ក្រសួងសាធារណការ និងដឹកជញ្ជូន

មានគោលនយោបាយចំនួន ១ គឺ ÷ អភិវឌ្ឍន៍ ថែទាំ និងគ្រប់គ្រងសំណង់សាធារណការ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមធ្យោបាយសេវាកម្មដឹកជញ្ជូនគ្រប់ប្រភេទ និងភស្តុភារកម្មប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

៤០៨ ៣២៦ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន២ គឺ÷

១. អភិវឌ្ឍន៍ ជួសជុល ថែទាំ និងគ្រប់គ្រងសំណង់សាធារណការ ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងភស្តុភារកម្ម

២. គាំទ្រគោលនយោបាយសាធារណការ, ដឹកជញ្ជូន, ការអភិវឌ្ឍន៍ធនធានមនុស្ស និងគ្រប់គ្រងរដ្ឋបាលទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១៥នៃឧបសម្ព័ន្ធ

## ក្រសួងអភិវឌ្ឍន៍ជនបទ

មានគោលនយោបាយចំនួន ១ គឺ ÷ លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្នទាំងផ្នែកសេដ្ឋកិច្ច សង្គមនិងវប្បធម៌។

១៨២ ៣៥៥ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ÷

១. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍
២. កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ
៣. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ
៤. ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ

គម្រោងចំណាយចរិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១៦នៃឧបសម្ព័ន្ធ

## ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

មានគោលនយោបាយចំនួន ១ គឺ ÷ បន្តអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

៧៧ ៦៥៥ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

១. ការការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យប្រៃសណីយ៍, ទូរគមនាគន៍ និងការគ្រប់គ្រងធនធានវិសាលគមន៍ប្រេកង់វិទ្យុ
២. ការគ្រប់គ្រង និងអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
៣. ការគាំទ្រផ្នែកស្ថាប័ន

គម្រោងចំណាយចរិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១៧នៃឧបសម្ព័ន្ធ

## ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

មានគោលនយោបាយចំនួន ១ គឺ ÷ ជំរុញ និងបង្កើនការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូចនិងមធ្យមវិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត ដើម្បីកំណើនសេដ្ឋកិច្ចជាតិ។

៥៦ ៩៦៦
លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៣ គឺ÷

១. ការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងការផ្គត់ផ្គង់ទឹកស្អាត

២. ការអភិវឌ្ឍស្តង់ដារ មាត្រាសាស្ត្រជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

៣. ការបង្កើនសេវាទ្រទ្រង់ដំណើរការកិច្ចការទូទៅ ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច និងមធ្យម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត។

គម្រោងចំណាយថវិកាឆ្នាំ **២០២០** ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១៨នៃឧបសម្ព័ន្ធ</u>

## រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

មានគោលនយោបាយចំនួន ១ គឺ ÷ លើកកម្ពស់គុណភាពសេវាកម្ម និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិលដើម្បី ធានាសុវត្ថិភាព និងសន្តិសុខសម្រាប់សហប្រតិបត្តិការដឹកជញ្ជូនផ្លូវអាកាស។

៤៩ ៥៥៥
លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ រដ្ឋលេខាធិការដ្ឋានបានរៀបចំកម្មវិធីចំនួន២ គឺ÷

១. សុវត្ថិភាព សន្តិសុខ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល

២. ការអភិវឌ្ឍស្ថាប័ន និងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>**តារាង ១៩នៃឧបសម្ព័ន្ធ**</u>

## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

មានគោលនយោបាយចំនួន ២ គឺ ÷

ទី ១ ÷ ពង្រឹង និងបង្កើនប្រសិទ្ធភាពគ្រប់គ្រងសេដ្ឋកិច្ច និងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។

ទី ២ ÷ ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ទ្រព្យសម្បត្តិរដ្ឋ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១. ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសេដ្ឋកិច្ច

២. ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង ការត្រួតពិនិត្យ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

៣. ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកៀរគរចំណូល ថវិកាជាតិ និងទ្រព្យសម្បត្តិរដ្ឋ

៤. ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយសាធារណៈ

៥. ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការគាំទ្រទូទៅនិងការធានាគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង<u>តារាង ២០ នៃឧបសម្ព័ន្ធ</u>

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

មានគោលនយោបាយចំនួន១ គឺ ÷ ពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សតាមរយៈការបោះឆ្នោត។

៣៧ ៤២២
លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ គជបបានរៀបចំកម្មវិធីចំនួន២ គឺ÷

១. រៀបចំបទបញ្ញា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត

២. កិច្ចដំណើរការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២១នៃឧបសម្ព័ន្ធ

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

មានគោលនយោបាយចំនួន១ គឺ ÷ កំណែទម្រង់វិស័យដីធ្លី និងការអភិវឌ្ឍន៍វិស័យសំណង់ និងលំនៅឋាន។

១០៩ ៩២៦
លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១. ពង្រឹងការគ្រប់គ្រងដីធ្លី

២. ពង្រឹងការរៀបចំដែនដី និងនគរូបនីយកម្ម

៣. ពង្រឹងការគ្រប់គ្រងវិស័យសំណង់

៤. ការគាំទ្រដំណើរការរដ្ឋបាល និងអភិវឌ្ឍន៍ស្ថាប័ន

៥. លំនៅឋាន

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២២នៃឧបសម្ព័ន្ធ

## ក្រសួងមុខងារសាធារណៈ

មានគោលនយោបាយចំនួន ១ គឺ ÷ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈ និងពង្រឹងការកែលម្អអភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ។

៥៦ ៥៣៤ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៤ គឺ÷

១. កំណែទម្រង់រដ្ឋបាលសាធារណៈ
២. ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យសាធារណៈ
៣. ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងការកែលម្អរបៀបរបបគ្រប់គ្រង និងចាត់ចែងការងារ
៤. ការគាំទ្រ និង ការសម្របសម្រួលទូទៅរបស់ក្រសួង និងមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៣នៃឧបសម្ព័ន្ធ

## ក្រសួងផែនការ

មានគោលនយោបាយចំនួន ១ គឺ ÷ អភិវឌ្ឍ និងជំរុញការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រវិស័យ ផែនការស្ថិតិ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

៩២ ៧៨៤ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១. អភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍក្នុងវិស័យផែនការ
២. ពង្រឹងប្រព័ន្ធស្ថិតិជាតិ
៣. សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០
៤. សម្របសម្រួល និងជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
៥. ការគាំទ្រកិច្ចការរដ្ឋបាលទូទៅ និងការអភិវឌ្ឍស្ថាប័ន

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៤នៃឧបសម្ព័ន្ធ

## ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

មានគោលនយោបាយចំនួន១ គឺ ÷ ពង្រឹង និងលើកកម្ពស់គោលនយោបាយការបរទេស ក្នុងការបន្តធ្វើ សមាហរណកម្មកម្ពុជាកាន់តែស៊ីជម្រៅទៅក្នុងតំបន់ និងពិភពលោក។

១៦១ ៤២៥
លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងពង្រីកទំនាក់ទំនងការងារការទូតនៅលើពិភពលោក

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ២៥នៃឧបសម្ព័ន្ធ</u>

## អង្គភាពប្រឆាំងអំពើពុករលួយ

មានគោលនយោបាយចំនួន ១ គឺ ÷ ពង្រឹងអភិបាលកិច្ចល្អតាមរយៈការកាត់បន្ថយអំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់។

៤២ ៥៤៩
លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ អង្គភាពបានរៀបចំកម្មវិធីចំនួន២ គឺ÷

១. វិធានការអប់រំបង្ការទប់ស្កាត់ និងអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ

២. សេវាកម្មគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ២៦នៃឧបសម្ព័ន្ធ</u>

## ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

មានគោលនយោបាយចំនួន១ គឺ ÷ លើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន និងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍ។

១៣ ៦៩១ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រុមប្រឹក្សាបានរៀបចំកម្មវិធីចំនួន ១ គឺ÷

ពង្រឹង និងពង្រីកវិស័យឯកជន និងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៧នៃឧបសម្ព័ន្ធ

## អជ្ញាធរសវនកម្មជាតិ

មានគោលនយោបាយចំនួន ១ គឺ ÷ រួមចំណែកលើកស្ទួយ អភិបាលកិច្ចល្អ និងការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

១២ ៩៤៨ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ អជ្ញាធរបានរៀបចំកម្មវិធីចំនួន ១ គឺ÷

ការគ្រប់គ្រង និងសម្របសម្រួលការងារសវនកម្ម

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៨នៃឧបសម្ព័ន្ធ

## ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

មានគោលនយោបាយចំនួន១ គឺ ÷ ការលើកកម្ពស់អភិបាលកិច្ចល្អតាមរយៈ ការអប់រំ បង្ការទប់ស្កាត់បាតុភាពអសកម្ម បង្កើនគណនេយ្យភាព ប្រសិទ្ធភាពការងារ និង ពង្រឹងនីតិរដ្ឋ។

៣៨ ៨៧៨ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

កិច្ចការទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ២៩នៃឧបសម្ព័ន្ធ</u>

## ក្រុមប្រឹក្សាធម្មនុញ្ញ

មានគោលនយោបាយចំនួន១ គឺ ÷ គោរពនីតិរដ្ឋ ការពារឯករាជ្យភាព អនុវត្តអព្យាក្រឹតភាពក្នុងការបំពេញមុខងារ។

១២ ៥២០ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រុមប្រឹក្សាបានរៀបចំកម្មវិធីចំនួន ១ គឺ÷

ធានាការគោរពនីតិរដ្ឋ ការពារឯករាជ្យភាព អនុវត្តអព្យាក្រឹតភាព

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣០នៃឧបសម្ព័ន្ធ</u>

## អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

មានគោលនយោបាយចំនួន១គឺ÷ពង្រឹងនិង លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

៣៦ ០៥២ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ អគ្គលេខាធិការដ្ឋាន បានរៀបចំកម្មវិធីចំនួន ១ គឺ÷

ការអនុវត្តមុខងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋាន

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣១នៃឧបសម្ព័ន្ធ</u>

## អគ្គលេខាធិការដ្ឋានរដ្ឋសភា

មានគោលនយោបាយចំនួន១គឺ÷លើកកម្ពស់នីតិរដ្ឋនិងលទ្ធិប្រជាធិបតេយ្យ តាមរយៈការអនុវត្តតួនាទីនៃមុខងារនីតិប្បញ្ញត្តិ និងជំរុញ សមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក។

១៦២ ៦៩៩ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ អគ្គលេខាធិការដ្ឋាន បានរៀបចំកម្មវិធីចំនួន ៣ គឺ÷

១. ការអនុវត្តមុខងារ និងតួនាទីនីតិប្បញ្ញត្តិរបស់ស្ថាប័នរដ្ឋសភា
២. កិច្ចការទូតរបស់រដ្ឋសភាក្នុងតំបន់ និងក្នុងពិភពលោក
៣. កិច្ចការធនធានមនុស្ស និងបង្កើនគុណភាពសេវាជូនរដ្ឋសភា

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣២នៃឧបសម្ព័ន្ធ</u>

## ក្រសួងព្រះបរមរាជវាំង

មានគោលនយោបាយចំនួន ១ គឺ ÷ បម្រើសេវាឱ្យកាន់តែល្អប្រសើរថ្វាយព្រះមហាក្សត្រ និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងការបំពេញព្រះរាជបេសកកម្មបម្រើប្រទេសជាតិ ឱ្យមានការអភិវឌ្ឍន៍ និងមានកិត្តិយសលើឆាកអន្តរជាតិតាមព្រះរាជកិច្ចរបស់ព្រះអង្គដែលរដ្ឋធម្មនុញ្ញបានកំណត់។

៧២ ៣៩៣ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

ព្រះរាជកិច្ច ព្រះមហាក្សត្រ និង សម្តេចព្រះវររាជមាតាជាតិខ្មែរ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣៣នៃឧបសម្ព័ន្ធ</u>

## ទីស្តីការគណៈរដ្ឋមន្ត្រី

មានគោលនយោបាយចំនួន១ គឺ ÷ បន្តដឹកនាំសម្របសម្រួលការរៀបចំ និងអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ដើម្បីការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រ។

៣៩៧ ១០១ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១គឺ÷

ពង្រឹងប្រសិទ្ធិភាពការកសាង និងអនុវត្តគោលនយោបាយនិងកំណែទម្រង់រដ្ឋ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣៤នៃឧបសម្ព័ន្ធ</u>

## ក្រសួងការពារជាតិ

មានគោលនយោបាយចំនួន ១ គឺ ៖ ការពារអធិបតេយ្យ បូរណភាពទឹកដី រក្សាសន្តិសុខ និងសុវត្ថិភាពសង្គម។

២ ៥៦៥ ៨៦២ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ៖

១. ដឹកនាំបញ្ជា ហ្វឹកហ្វឺន ធ្វើប្រតិបត្តិការ ការពារសុខសន្តិភាព និងរក្សាសណ្តាប់ធ្នាប់សង្គម

២. សហប្រតិបត្តិការយោធាក្នុងតំបន់ និងអន្តរជាតិ

៣. ថែទាំគ្រឿងបំពាក់បច្ចេកទេស វិស្វកម្ម និងបញ្ជូនសារ

៤. សេវាគាំទ្ររដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣៥នៃឧបសម្ព័ន្ធ

## ក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ)

មានគោលនយោបាយចំនួន ១ គឺ ៖ ពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ។

១ ៦៨៦ ៨៥៨ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ៖

១. ការការពារសន្តិសុខជាតិ និងការរក្សាសណ្តាប់ធ្នាប់សាធារណៈ

២. កិច្ចការអត្តសញ្ញាណបុគ្គល និងអន្តោប្រវេសន៍

៣. កិច្ចការសន្តិសុខមិនប្រពៃណី

៤. សេវាគាំទ្រកិច្ចប្រតិបត្តិការទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣៦នៃឧបសម្ព័ន្ធ

## ក្រសួងមហាផ្ទៃ (ផ្នែករដ្ឋបាលទូទៅ)

មានគោលនយោបាយចំនួន ១ គឺ ÷ ដឹកនាំ គ្រប់គ្រងរដ្ឋបាលដែនដី ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍ។

២៩៨ ៤០៧ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

១. ការគ្រប់គ្រងរដ្ឋបាលដែនដី

២. ការគ្រប់គ្រងពន្ធនាគារ

៣. សេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣៧នៃឧបសម្ព័ន្ធ

## ក្រសួងយុត្តិធម៌

មានគោលនយោបាយចំនួន ១ គឺ ÷ បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌។

១៦៤ ៧៨២ លានរៀល

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

១. កិច្ចការច្បាប់

២. កិច្ចការតុលាការ

៣. សេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០២១ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣៨នៃឧបសម្ព័ន្ធ

## ៣.៤. ការកំណត់ពិតានៃការខ្ចីសម្រាប់ឆ្នាំ ២០២១

រាជរដ្ឋាភិបាលកំណត់ទំហំនៃការខ្ចីប្រាក់ពីដៃគូអភិវឌ្ឍន៍សម្រាប់ឆ្នាំ ២០២១ ក្នុងកម្រិត ១ ៥០០ លានSDR ដោយឈរលើមូលដ្ឋាននៃការគិតគូរ និងផ្អែកទៅលើទិដ្ឋភាពសំខាន់ៗមួយចំនួនដែលរួមមាន÷ **(១)**-ទំហំនៃតម្រូវការវិនិយោគសាធារណៈមានការកើនឡើងជាគំហុក ដើម្បីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ឆ្លើយតបនឹងបរិការណ៍នៃផលប៉ះពាល់ពីការរីករាលដាលជំងឺកូវីដ-១៩, **(២)**-គម្រោងអភិវឌ្ឍន៍ដែលនឹងចុះកិច្ចព្រមព្រៀងឥណទានសម្បទានក្នុងឆ្នាំ ២០២១ ជាគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាព (ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការបង្កើនផលិតភាពសេដ្ឋកិច្ច និងផលិតភាពផលិតកម្ម) ហើយដែលចេះតែរំកិលពីឆ្នាំមុនៗមក តែមានចរិតយុទ្ធសាស្ត្រក្នុងការទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងវែង, **(៣)**-ឥណទានមានកម្រិតសម្បទានខ្ពស់, **(៤)**-ស្ថានភាពបំណុលសាធារណៈកម្ពុជាបច្ចុប្បន្ន និងក្នុងរយៈពេលមធ្យមនៅតែមាន "**ចីរភាព**" និង "**ហានិភ័យកម្រិតទាប**" និង **(៥)**-ការបន្តបង្កើនប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង។ ជាក់ស្តែង ផ្អែកលើលទ្ធផលនៃការវិភាគចីរភាពបំណុល ដោយឈរលើមូលដ្ឋានសន្មតិនៃការខ្ចីថ្មីបន្ថែមសម្រាប់ឆ្នាំ ២០២១ ក្នុងកម្រិត ១ ៥00 លានSDR គឺបានបង្ហាញថាសូចនាករបំណុលគន្លឹះទាំង ៤ របស់កម្ពុជាសុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់។

ក្នុងការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលតែងតែប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះចំនួន ៥ ដូចខាងក្រោម÷

១ ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន

២ ខ្ចីតែឥណទានដែលមានកម្រិតសម្បទានឬលក្ខខណ្ឌអនុគ្រោះខ្ពស់

៣ ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចនិងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម

៤ ប្រើប្រាស់ឥណទាន ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និង ស័ក្តិសិទ្ធភាពខ្ពស់បំផុត;

៥ ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍ-ជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់នឹងបម្រែបម្រួលអាកាសធាតុ។

ក្នុងន័យនេះ ការកំណត់ពិដានក្នុងការខ្ចីថ្មីសម្រាប់ឆ្នាំ២០២១ ក្នុងកម្រិត១ ៥00 លាន SDR គឺដើម្បីឱ្យរាជរដ្ឋាភិបាលអាចចុះហត្ថលេខាខ្ចីប្រាក់ពីគេសម្រាប់ហិរញ្ញប្បទានកម្មវិធី/គម្រោងវិនិយោគសាធារណៈចំនួន ៣៦ ដែលរួមមាន÷ ធនាគារពិភពលោកចំនួន ៥គម្រោង, ធនាគារអភិវឌ្ឍន៍អាស៊ីចំនួន ៩គម្រោង, ធនាគារវិនិយោគអឺរ៉ុបចំនួន ២គម្រោង, ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ីចំនួន ១គម្រោង, ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ចំនួន ១គម្រោង, សាធារណរដ្ឋប្រជាមានិតចិនចំនួន ៧គម្រោង, ប្រទេសជប៉ុនចំនួន ២គម្រោង, សាធារណរដ្ឋកូរ៉េចំនួន ៦គម្រោង, សាធារណរដ្ឋបារាំងចំនួន ២គម្រោង, និងព្រះរាជាណាចក្រថៃចំនួន ១គម្រោង ដោយបែងចែកតាមវិស័យ ដូចខាងក្រោម÷

- <u>វិស័យថាមពល÷</u> គម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់របស់ខ្សែបណ្តាញបញ្ជូនអគ្គិសនីតង់ស្យុង ១១៥ គីឡូវ៉ុលភ្នំពេញ-បាវិត, គម្រោងសាងសង់អនុស្ថានីយ៍បន្ថែមនៅតំបន់ជុំវិញរាជធានីភ្នំពេញ, គម្រោងពង្រឹងសមត្ថភាពប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី, គម្រោងប្រសិទ្ធភាពថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទ ដំណាក់កាលទី២ និងគម្រោងសាងសង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ៥០០ គីឡូវ៉ុល ពីអនុស្ថានីយអគ្គិសនីខាងកើតរាជធានីភ្នំពេញ មកអនុស្ថានីយ៍អគ្គិសនីស្ទឹង និងខ្សែបញ្ជូនរង ២២ គីឡូវ៉ុល ក្នុងខេត្តត្បូងឃ្មុំ និងខេត្តព្រៃវែង ក្នុងគោលដៅពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះថ្លៃអគ្គិសនីនៅជនបទ ដើម្បីរួមចំណែកកាត់បន្ថយចំណាយរបស់ប្រជាជននៅជនបទផង និងកាត់បន្ថយថ្លៃដើមផលិតកម្មក្នុងវិស័យកសិកម្ម និងសិប្បកម្ម/ឧស្សាហកម្មជនបទផង;
- <u>វិស័យធារាសាស្ត្រ÷</u> គម្រោងអភិវឌ្ឍន៍អាងទឹកដងកាំបិត ខេត្តកំពង់ធំ, កម្មវិធីគ្រប់គ្រងធនធានទឹក និងការផ្លាស់ប្តូរវិស័យកសិកម្ម ដំណាក់កាលទី២ និងគម្រោងកែលម្អធារាសាស្ត្រកសិកម្ម;
- <u>វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត÷</u> គម្រោងធ្វើឱ្យប្រសើរឡើងផ្លូវជាតិលេខ៣១ (បែកគួសកំពង់ត្រាច-ផ្លូវជាតិលេខ៣៣), គម្រោងធ្វើឱ្យប្រសើរឡើងផ្លូវជាតិលេខ៣៣ (ផ្លូវជាតិលេខ៣ គម ១៤៨+១០០-ព្រំប្រទល់ កម្ពុជា-វៀតណាម), គម្រោងធ្វើឱ្យប្រសើរឡើងផ្លូវជាតិលេខ៤១ (ថ្នល់ទទឹង ផ្លូវជាតិលេខ៤-ផ្លូវជាតិលេខ៣ គម ១២៦+៧៥៥), គម្រោងសាងសង់ស្ពានទន្លេមេគង្គ ខេត្តក្រចេះ, គម្រោងលើកកម្ពស់ផ្លូវជាតិលេខ៧ (ស្គន់-កំពង់ចាម), គម្រោងរៀបចំច្រកទ្វារអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ផ្លូវជាតិលេខ៥ ដំណាក់កាលទី២, គម្រោងធ្វើឱ្យប្រសើរឡើងនូវកំណាត់ផ្លូវជាតិលេខ៥ ភាគខាងត្បូង, គម្រោងសាងសង់ផ្លូវវាងក្រុងសៀមរាប, គម្រោងសាងសង់ស្ពានមិត្តភាពកម្ពុជា-កូរ៉េ, គម្រោងកែលម្អការថែទាំផ្លូវ ដំណាក់កាលទី២ និងគម្រោងលើកកម្ពស់សមត្ថភាពបន្សាំនៅជនបទ;
- <u>វិស័យអាទិភាពផ្សេងទៀត÷</u> គម្រោងធ្វើឱ្យប្រសើរឡើងមន្ទីរពេទ្យបង្អែកខេត្ត, គម្រោងទប់ស្កាត់ និងបង្ការជំងឺឆ្លងក្នុងមហាតំបន់មេគង្គ, គម្រោងទប់ស្កាត់និងបង្ការជំងឺឆ្លងនៅក្នុងតំបន់

សេដ្ឋកិច្ចពិសេសនៅតាមព្រំដែន ក្នុងមហាអនុតំបន់មេគង្គ, គម្រោងលើកម្ពស់គុណភាព និងសមធម៌សុខាភិបាល ដំណាក់កាលទី២, កម្មវិធីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីអភិវឌ្ឍន៍ហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន, គម្រោងលើកកម្ពស់ការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម, គម្រោងអភិវឌ្ឍន៍ទេសចរណ៍ និងនេសាទនៅតាមតំបន់ឆ្នេរ, កម្មវិធីវិនិយោគក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅមធ្យមសិក្សាទុតិយភូមិ, គម្រោងគាំទ្រវិស័យអប់រំ, គម្រោងគាំទ្រការសិក្សាសមិទ្ធិលទ្ធភាពនិងការអនុវត្តគម្រោង, គម្រោងគ្រប់គ្រងធនធានធម្មជាតិ, គម្រោងគ្រប់គ្រងកាកសំណល់រឹង, គម្រោងអភិវឌ្ឍន៍ទីក្រុងគួរឱ្យចង់រស់នៅ ដំណាក់កាលទី១, គម្រោងផ្គត់ផ្គង់ទឹកស្អាតសៀមរាប, គម្រោងសាងសង់ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់ និងបណ្តាញលូនៅសៀមរាប ដំណាក់កាលទី២ និងគម្រោងគាំទ្រនិរន្តរភាពហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីទីផ្សារកសិករ និងពាណិជ្ជូបនីយកម្មកសិកម្ម។

## ៣.៥. គម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ




គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក និង ឃុំ-សង្កាត់ មានឱនភាពថវិកាចំនួន ១ ០៦០ ៤៥០ លានរៀល ដែលត្រូវបានឧបត្ថម្ភដោយថវិកាថ្នាក់ជាតិ ហើយការឧបត្ថម្ភនេះថយចុះ ២,៣% ធៀបនឹងច្បាប់ឆ្នាំ ២០២០ ហើយត្រូវជា ០,៩១% នៃ ផសស ក្នុងនោះ៖

(១)- ឧបត្ថម្ភរាជធានី-ខេត្ត ចំនួន ១២ ៨០៧ លានរៀល ដើម្បីអនុវត្តការផ្ទេរមុខងាររបស់មន្ទីរជំនាញ,

(២)- ឧបត្ថម្ភក្រុង-ស្រុក ចំនួន ៣៣៨ ០៩៥ លានរៀល, មានកំណើន ៤៣,៨% ធៀបនឹងច្បាប់ឆ្នាំ ២០២០;,

(៣)- ឧបត្ថម្ភមូលនិធិឃុំ-សង្កាត់ ចំនួន ៥៤០ ៦០៨ លានរៀល, ថយចុះ ១១,០% ធៀបនឹងច្បាប់ឆ្នាំ ២០២០, និង

(៤)- មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ ចំនួន ១៦៨ ៩៤០ លានរៀល, ស្មើនឹង ០,១៤% នៃ ផសស, ដែលជាការផ្ទេរធនធានបន្ថែមជូនរដ្ឋបាលឃុំ-សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៣។ ការឧបត្ថម្ភធនបន្ថែមនេះ នឹងធ្វើឱ្យរដ្ឋបាលឃុំ-សង្កាត់នីមួយៗ ទទួលបានជាមធ្យមប្រមាណ ២៤២ លានរៀល ឬសមមូលនឹង ៦០ ០០០ ដុល្លារអាមេរិក ជាមធ្យមក្នុង ១ ឆ្នាំ។

ប្រាក់បំណាច់របស់ក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងឆ្នាំ ២០២១ ត្រូវបានរក្សាស្មើនឹងកម្រិតឆ្នាំ២០២០។ ដូចនេះ ប្រាក់បំណាច់របស់ក្រុមប្រឹក្សារាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ក៏ដូចជាក្រុមប្រឹក្សាឃុំ-សង្កាត់ និងមន្ត្រីភូមិ ត្រូវបានផ្តល់ជូនដូចខាងក្រោម÷

### ក្រុមប្រឹក្សារាជធានី-ខេត្ត

- ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សារាជធានី-ខេត្ត ទទួលបានចំនួន
  **១ ៤៤០ ០០០** រៀល
- ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត ទទួលបានចំនួន
  **១ ១៣៥ ០០០** រៀល

### ក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ

- ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ ទទួលបានចំនួន
  **១ ១៥៥ ០០០** រៀល
- ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ ទទួលបានចំនួន
  **៩១០ ០០០** រៀល

### ក្រុមប្រឹក្សាឃុំ-សង្កាត់

- ប្រាក់បំណាច់មេឃុំ ចៅសង្កាត់ ទទួលបានចំនួន ១ ១១០ ០០០ រៀល
- ប្រាក់បំណាច់ជំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២ ទទួលបានចំនួន ៨៧០ ០០០ រៀល
- ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាឃុំ- សង្កាត់ ទទួលបានចំនួន ៧៦០ ០០០ រៀល
- ប្រាក់បំណាច់មេភូមិ ទទួលបានចំនួន ៤៣០ ០០០ រៀល
- ប្រាក់បំណាច់អនុប្រធានភូមិ ទទួលបានចំនួន ៣១០ ០០០ រៀល
- ប្រាក់បំណាច់សមាជិកភូមិ ទទួលបានចំនួន ២៨០ ០០០ រៀល។

## ៣.៦. ស្ថានភាពបំណុល

សន្និធិបំណុលសាធារណៈក្រៅប្រទេស គិតត្រឹមដំណាច់ត្រីមាសទី៣ ឆ្នាំ ២០២០



# អនុបាតបំណុលគន្លឹះទាំង ៤

អនុបាតសន្និធិបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផសស




អនុបាតសន្និធិបំណុលសាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញ




អនុបាតសេវាបំណុលធៀបនឹងការនាំចេញ




អនុបាតសេវាបំណុលធៀបនឹងចំណូលថវិកាជាតិ




តម្លៃចារឹក តម្លៃបច្ចុប្បន្ន សេវាបំណុល អនុបាតគោល

# ជំពូក

# ៤

## បទប្បញ្ញត្តិស្តីពីពន្ធដារ

ក្នុងគោលដៅកែសម្រួល និង បំពេញបន្ថែមនូវលិខិតបទដ្ឋានគតិយុត្តនានា សំដៅធានាឱ្យនីតិវិធីប្រមូលពន្ធប្រព្រឹត្តទៅប្រកបដោយភាពស៊ីសង្វាក់ប្រទាក់ប្រឡា រលូន និងប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព ក្នុងបរិការណ៍សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និង សកលលោក, វិធានការដូចខាងក្រោម ត្រូវបានស្នើដាក់ចេញ ÷

**ទី១. ធ្វើវិសោធនកម្មមាត្រា ៧២ នៃច្បាប់ស្តីពីសារពើពន្ធ ដោយធ្វើការកែសម្រួល បញ្ចូលខ្លឹមសារបន្ថែមទាក់ទិននឹងការដាក់ឱ្យអនុវត្តយន្តការបង្វិលសងអាករលើតម្លៃបន្ថែម សម្រាប់ទេសចរ** ដើម្បីធានាបាននូវចីរភាពកំណើនសេដ្ឋកិច្ច និង គាំទ្រគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលចំពោះទេសចរបរទេស សំដៅជំរុញបរិយាកាសវិនិយោគនៅកម្ពុជាឱ្យកាន់តែល្អប្រសើរ និង ក្នុងគោលបំណងទាក់ទាញទេសចរបរទេសឱ្យមកកំសាន្តនៅព្រះរាជាណាចក្រកម្ពុជា និង ទិញទំនិញសម្រាប់យកទៅប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជាឱ្យមានការកើនឡើងកាន់តែច្រើន។

**ទី២. ធ្វើវិសោធនកម្មមាត្រា ៤០ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដោយអនុគ្រោះលុបការបង់ពន្ធប្រថាប់ត្រា ១ 000 000 រៀល ចំពោះការចុះបញ្ជីពន្ធដារ** ដើម្បីកែលម្អបរិយាកាសវិនិយោគនៅកម្ពុជាឱ្យកាន់តែមានភាពងាយស្រួល និង គាំទ្រដល់ការដាក់ឱ្យអនុវត្តការចុះបញ្ជីពន្ធដារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (IT Platform) តែមួយកន្លែង និង សម្រាលបន្ទុកចំណាយលើការចុះបញ្ជី។

*ចំណាំ÷ *សម្រាប់ខ្លឹមសារលម្អិតនៃបទប្បញ្ញត្តិស្តីពីពន្ធដារ គឺមានចែងនៅក្នុងជំពូកទី៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ដែលបានដាក់ផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។*

# ជំពូក

# ៤

## សេចក្ដីសន្និដ្ឋាន

ថវិកាឆ្នាំ ២០២១ ត្រូវបានគិតគូរ និងរៀបចំឡើង ក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ ដើម្បីតម្រង់ការប្រើប្រាស់ធនធានសម្រាប់ទ្រទ្រង់ដល់និរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងសម្រាប់ការរក្សាលំនឹងសង្គម-សេដ្ឋកិច្ចកម្ពុជា និងជីវភាពរបស់ប្រជាជន ព្រមទាំងការស្តារ និងជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ច ក៏ដូចជាដើម្បីសម្រេចឱ្យបាននូវគោលដៅសំខាន់ៗ នៃ **កម្មវិធីនយោបាយ យុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី ៤ និង ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣** ពិសេស ការជំរុញអនុវត្តកិច្ចការកែទម្រង់គ្រប់វិស័យក្នុងឆ្នាំ ២០២១ ដែលជាឆ្នាំពាក់កណ្តាលអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ សំដៅឈានទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជន ដែលចង់ឱ្យកម្ពុជាក្លាយជាប្រទេសមានមោទនភាពជាតិ មានអនាគតដ៏រុងរឿង ភ្លឺស្វាង ត្រចះត្រចង់ និងជារដ្ឋអធិបតេយ្យមួយរឹងមាំដែលគោរពខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ។ ទន្ទឹមនេះ, ក្របខណ្ឌថវិកាឆ្នាំ ២០២១ ក៏មានគោលដៅបន្តរក្សាការពារសមិទ្ធផលសង្គមជាតិទាំងឡាយ ដែលសម្រេចបានក្នុងរយៈពេលជាង២ទសវត្សរ៍កន្លងមកប្រកបដោយភាពជាម្ចាស់ ព្រមជាមួយនឹងការខិតខំប្រឹងប្រែង ដើម្បីជម្នះ និងទប់ទល់ផលប៉ះពាល់អវិជ្ជមាននានាបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងបញ្ហាប្រឈមផ្សេងៗទៀត, ទាំងក្នុង និងក្រៅប្រទេស, ដើម្បីកម្ពុជាអាចឈររឹងមាំ និងធ្វើជាម្ចាស់លើជោគវាសនារបស់ខ្លួន, ទាំងនៅក្នុងពេលបច្ចុប្បន្ន និងតទៅអនាគត។



សរុបមក, ថវិកាឆ្នាំ ២០២១ ជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលអាចជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង, ទាំងក្នុង និងក្រៅប្រទេស, ដែលត្រូវបានប្រសិទ្ធនាមថាជា **"ថវិកាប្រយុទ្ធការពារអាយុជីវិតប្រជាជន, រក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជន ព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ នៅក្រោយពេលស្រាកស្រាន្តពីវិបត្តិជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ដើម្បីធានាសុខសន្តិភាព ស្ថិរភាពសង្គម និងចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងភាពប្រកួតប្រជែងរបស់កម្ពុជា ជាមួយនឹងការបន្តលើកស្ទួយសុខុមាលភាពរបស់ប្រជាជន"៕**

# ជំពូក




## តារាងឧបសម្ព័ន្ធ

# ៦.១. គម្រោងចំណាយថវិកាចរន្តរបស់ក្រសួង ស្ថាប័ន តាមកម្មវិធី អនុកម្មវិធី

ឯកតា លានរៀល

| តារាង ១ ÷ គម្រោងចំណាយថវិកាក្រសួងអប់រំ យុវជន និងកីឡា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| សរុបរួម | **3,024,413.0** |
| **១.កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ** | **281,501.1** |
| ១.១.អនុកម្មវិធីទី១៖ការពង្រីកការអប់រំកុមារតូច | 13,296.0 |
| ១.២.អនុកម្មវិធីទី២៖ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា | 2,415.1 |
| ១.៣.អនុកម្មវិធីទី៣៖ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា | 6,808.7 |
| ១.៤.អនុកម្មវិធីទី៤៖ការពង្រីកការអប់រំក្រៅប្រព័ន្ធ | 1,878.3 |
| ១.៥.អនុកម្មវិធីទី៥៖ការពង្រឹង និងការពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា | 668.7 |
| ១.៦.អនុកម្មវិធីទី៦៖លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស | 2,674.2 |
| ១.៧.អនុកម្មវិធីទី៧៖ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន | 8,835.8 |
| ១.៨.អនុកម្មវិធីទី៨៖ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ | 27,843.1 |
| ១.៩.អនុកម្មវិធីទី៩៖ពង្រីកការអប់រំបរិយាបន្នគ្រប់ភូមិសិក្សា | 779.6 |
| ១.១០.អនុកម្មវិធីទី១០៖ សេវាគាំទ្រការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការរបស់មន្ទីរជំនាញរាជធានី ខេត្ត | 216,301.6 |
| **២.កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ** | **30,119.0** |
| ២.១.អនុកម្មវិធីទី១៖ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា | 2,475.0 |
| ២.២.អនុកម្មវិធីទី២៖ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា | 835.3 |
| ២.៣.អនុកម្មវិធីទី៣៖ការពង្រឹងគុណភាព និងភាពឆ្លើយតបនៃការបណ្តុះបណ្តាលកម្រិតឧត្តម និងក្រោយឧត្តមប្រកបដោយប្រសិទ្ធភាព | 3,423.3 |
| ២.៤.អនុកម្មវិធីទី៤៖ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវ | 1,238.9 |
| ២.៥.អនុកម្មវិធីទី៥៖ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ | 2,195.0 |
| ២.៦.អនុកម្មវិធីទី៦៖ការអភិវឌ្ឍការបណ្តុះបណ្តាល និងស្រាវជ្រាវ | 3,926.9 |
| ២.៧.អនុកម្មវិធីទី៧៖ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ | 4,700.1 |
| ២.៨.អនុកម្មវិធីទី៨៖ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ | 3,035.5 |
| ២.៩.អនុកម្មវិធីទី៩៖ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ | 1,480.2 |
| ២.១០.អនុកម្មវិធីទី១០៖ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវ | 1,940.3 |
| ២.១១.អនុកម្មវិធីទី១១៖លើកកម្ពស់គុណភាពបណ្តុះបណ្តាល ស្រាវជ្រាវ និងសហគ្រិនភាព | 0.0 |
| ២.១២.អនុកម្មវិធីទី១២៖ការពង្រឹងគុណភាពប្រសិទ្ធភាពអប់រំ និងការស្រាវជ្រាវ | 0.0 |
| ២.១៣.អនុកម្មវិធីទី១៣៖ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា | 724.7 |
| ២.១៤.អនុកម្មវិធីទី១៤៖ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវលើផ្នែកបច្ចេកទេស វិជ្ជាជីវៈ និងសេវាសហគមន៍ | 1,882.1 |

| តារាង ១ ÷ គម្រោងចំណាយថវិកាក្រសួងអប់រំ យុវជន និងកីឡា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| ២.១៥.អនុកម្មវិធីទី១៥៖ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ | 1,074.5 |
| ២.១៦.អនុកម្មវិធីទី១៦៖ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវលើផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ | 1,187.2 |
| **៣.កម្មវិធីទី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា** | **62,933.9** |
| ៣.១.អនុកម្មវិធីទី១៖ការអភិវឌ្ឍកីឡាមហាជន | 5,721.2 |
| ៣.២.អនុកម្មវិធីទី២៖ការអភិវឌ្ឍអប់រំកាយ និងកីឡាសិស្ស និស្សិត | 3,048.9 |
| ៣.៣.អនុកម្មវិធីទី៣៖ការបណ្តុះបណ្តាលធនធានមនុស្សផ្នែកអប់រំកាយ និងកីឡា | 1,647.9 |
| ៣.៤.អនុកម្មវិធីទី៤៖ការអភិវឌ្ឍកីឡាកម្រិតខ្ពស់ | 28,320.5 |
| ៣.៥.អនុកម្មវិធីទី៥៖ការអភិវឌ្ឍការប្រកួត និងគ្រប់គ្រងព្រឹត្តិការណ៍កីឡាគ្រប់កម្រិត | 5,481.5 |
| ៣.៦.អនុកម្មវិធីទី៦៖ការអភិវឌ្ឍផ្នែកព័ត៌មាន និងស្ថិតិកីឡាគ្រប់ប្រភេទ | 500.0 |
| ៣.៧.អនុកម្មវិធីទី៧៖សេវាគាំទ្រការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡារបស់មន្ទីរជំនាញរាជធានី ខេត្ត | 18,213.9 |
| **៤.កម្មវិធីទី៤៖ ការអភិវឌ្ឍជំនាញបច្ចេកទេស ជំនាញទន់និងសហគ្រិនភាពសម្រាប់យុវជន** | **15,582.8** |
| ៤.១.អនុកម្មវិធីទី១៖ការពង្រឹងសមត្ថភាពយុវជន | 5,878.3 |
| ៤.២.អនុកម្មវិធីទី២៖ការអភិវឌ្ឍមជ្ឈមណ្ឌលយុវជន | 2,684.2 |
| ៤.៣.អនុកម្មវិធីទី៣៖ការអភិវឌ្ឍកាយរឹទ្ធិកម្ម | 1,111.5 |
| ៤.៤.អនុកម្មវិធីទី៤៖សេវាគាំទ្រអភិវឌ្ឍជំនាញបច្ចេកទេស និងជំនាញទន់សម្រាប់យុវជនរបស់មន្ទីរជំនាញរាជធានី ខេត្ត | 5,908.8 |
| **៥.កម្មវិធីទី៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ** | **2,634,276.2** |
| ៥.១.អនុកម្មវិធីទី១៖ការអភិវឌ្ឍនិងពង្រឹងប្រព័ន្ធផែនការអប់រំ | 1,352.4 |
| ៥.២.អនុកម្មវិធីទី២៖ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស | 109,564.5 |
| ៥.៣.អនុកម្មវិធីទី៣៖ការអភិវឌ្ឍសមត្ថភាព ការងារគ្រប់គ្រង ផែនការហិរញ្ញវត្ថុ និងមូលដ្ឋានសម្ភារៈ | 49,139.5 |
| ៥.៤.អនុកម្មវិធីទី៤៖ពង្រឹងការងារសវនកម្មផ្ទៃក្នុង | 612.7 |
| ៥.៥.អនុកម្មវិធីទី៥៖ការវាយតម្លៃលទ្ធផលសិក្សា និងអធិការកិច្ចគុណភាពអប់រំ | 2,397.5 |
| ៥.៦.អនុកម្មវិធីទី៦៖អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ | 489.8 |
| ៥.៧.អនុកម្មវិធីទី៧៖ការប្រមូល ផ្សព្វផ្សាយព័ត៌មានអប់រំ និងសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាននិង ស៊ីមេអូ | 967.7 |
| ៥.៨.អនុកម្មវិធីទី៨៖ការពង្រឹងការងារនីតិកម្ម | 713.0 |
| ៥.៩.អនុកម្មវិធីទី៩៖ការពង្រឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ | 6,461.6 |
| ៥.១០.អនុកម្មវិធីទី១០៖ការពង្រឹងការគ្រប់គ្រង ការផ្គត់ផ្គង់សម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | 2,368.0 |
| ៥.១១.អនុកម្មវិធីទី១១៖ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការធានាភាពស័ក្តិសិទ្ធនៃសេវារដ្ឋបាលអប់រំ | 2,319.2 |

| តារាង ១ ÷ គម្រោងចំណាយថវិកាក្រសួងអប់រំ យុវជន និងកីឡា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| ៥.១២.អនុកម្មវិធីទី១២៖ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិលើវិស័យអប់រំ | 4,882.5 |
| ៥.១៣.អនុកម្មវិធីទី១៣៖ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | 1,136.8 |
| ៥.១៤.អនុកម្មវិធីទី១៤៖អភិវឌ្ឍគោលនយោបាយអប់រំ និងការស្រាវជ្រាវ | 1,694.6 |
| ៥.១៥.អនុកម្មវិធីទី១៥៖អភិវឌ្ឍប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ | 701.5 |
| ៥.១៦.អនុកម្មវិធីទី១៦៖ការអភិវឌ្ឍនិងពង្រឹងប្រព័ន្ធព័ត៌មានវិទ្យា | 795.9 |
| ៥.១៧.អនុកម្មវិធីទី១៧៖ការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារប្រឡងនៅមធ្យមសិក្សានិងអប់រំបច្ចេកទេស | 28,015.2 |
| ៥.១៨.អនុកម្មវិធីទី១៨៖សេវាគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ របស់មន្ទីរជំនាញរាជធានី ខេត្ត | 2,420,663.8 |

| តារាង ២ ÷ គម្រោង ចំណាយ ថវិកាក្រសួងសុខាភិបាល តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| **សរុបរួម** | **1,720,684.0** |
| **១.កម្មវិធីទី ១ ÷ សុខភាពបន្តពូជ យុវវ័យ មាតា ទារក កុមារ និងអាហារូបត្ថម្ភ** | **117,082.7** |
| ១.១.អនុកម្មវិធីទី ១ ÷ អាហារូបត្ថម្ភ | *827.4* |
| ១.២.អនុកម្មវិធីទី ២ ៖ សុខភាពបន្តពូជ | *8,990.8* |
| ១.៣.អនុកម្មវិធីទី ៣ ៖ សុខភាពមាតា និងទារក | *6,174.8* |
| ១.៤.អនុកម្មវិធីទី ៤ ៖ សុខភាពកុមារ | *90,734.5* |
| ១.៥.អនុកម្មវិធីទី ៥ ៖ សេវាគាំទ្រសុខភាពបន្តពូជ យុវវ័យ មាតា ទារក កុមារ និងអាហារូបត្ថម្ភ សម្រាប់ថ្នាក់រាជធានី ខេត្ត | *10,355.2* |
| **២.កម្មវិធីទី ២ ÷ ប្រយុទ្ធជំងឺឆ្លង** | **25,362.0** |
| ២.១.អនុកម្មវិធីទី ១ ៖ បង្ការ និងថែទាំព្យាបាលជំងឺអេដស៍ | *12,478.0* |
| ២.២.អនុកម្មវិធីទី ២ ៖ បង្ការ និងថែទាំព្យាបាលជំងឺរបេង | *9,019.8* |
| ២.៣.អនុកម្មវិធីទី ៣ ៖ បង្ការ និងថែទាំព្យាបាលជំងឺគ្រុនចាញ់ និងគ្រុនឈាម | *1,228.9* |
| ២.៤.អនុកម្មវិធីទី ៤ ៖ បង្ការ និងឆ្លើយតបជំងឺឆ្លងដទៃទៀត | *620.7* |
| ២.៥.អនុកម្មវិធីទី ៥ ៖ សេវាគាំទ្រប្រយុទ្ធជំងឺឆ្លង សម្រាប់ថ្នាក់រាជធានី ខេត្ត | *2,014.6* |
| **៣.កម្មវិធីទី ៣ ÷ ប្រយុទ្ធជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត** | **2,586.9** |
| ៣.១.អនុកម្មវិធីទី ១ ៖ សុខភាពភ្នែក | *100.0* |
| ៣.២.អនុកម្មវិធីទី ២ ៖ សុខភាពផ្លូវចិត្ត និងបំពានគ្រឿងញៀន | *472.6* |
| ៣.៣.អនុកម្មវិធីទី ៣ ៖ សុខភាពមាត់-ធ្មេញ | *107.3* |
| ៣.៤.អនុកម្មវិធីទី ៤ ៖ ជំងឺរ៉ាំរ៉ៃ | *59.6* |
| ៣.៥.អនុកម្មវិធីទី ៥ ៖ បញ្ហាសុខភាពសាធារណៈផ្សេងៗទៀត | *830.9* |
| ៣.៦.អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រប្រយុទ្ធជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត សម្រាប់ថ្នាក់រាជធានី ខេត្ត | *1,016.5* |
| **៤.កម្មវិធីទី ៤ ÷ ពង្រឹងប្រព័ន្ធសុខាភិបាល** | **1,575,652.4** |
| ៤.១.អនុកម្មវិធីទី ១ ៖ ការផ្តល់សេវាសុខាភិបាល | *777,274.4* |
| ៤.២.អនុកម្មវិធីទី ២ ៖ ហិរញ្ញប្បទានសុខាភិបាល | *5,075.9* |
| ៤.៣.អនុកម្មវិធីទី ៣ ៖ អភិវឌ្ឍន៍ធនធានមនុស្ស | *100,829.6* |
| ៤.៤.អនុកម្មវិធីទី ៤ ៖ ប្រព័ន្ធព័ត៌មានសុខាភិបាល | *126.0* |
| ៤.៥.អនុកម្មវិធីទី ៥ ៖ អភិបាលកិច្ចវិស័យសុខាភិបាល | *2,884.8* |
| ៤.៦.អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រពង្រឹងប្រព័ន្ធសុខាភិបាល នៃរដ្ឋបាលរាជធានី ខេត្ត | *689,461.7* |

| តារាង ៣ ÷ គម្រោង ចំណាយ ថវិកាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| **សរុបរួម** | **1,287,695.0** |
| **១. កម្មវិធីទី ១ ÷ សេវាសុខុមាលភាពសង្គម** | **70,434.9** |
| ១.១. អនុកម្មវិធីទី ១ ៖ ការផ្តល់សេវាសុខុមាលភាពប្រជាជនក្រីក្រនិងជនរងគ្រោះនៅតាមសហគមន៍ | *40,221.2* |
| ១.២. អនុកម្មវិធីទី ២ ៖ កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ | *57.2* |
| ១.៣. អនុកម្មវិធីទី ៣ ៖ ការផ្តល់សេវាសុខុមាលភាព និងកិច្ចការពារកុមារ | *1,076.1* |
| ១.៤. អនុកម្មវិធីទី ៤ ៖ កិច្ចការពារអនីតិជនទំនាស់នឹងច្បាប់ និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន | *3,330.0* |
| ១.៥. អនុកម្មវិធីទី ៥ ៖ ការផ្តល់សេវាសុខុមាលភាព និងកិច្ចការពារជនមានពិការភាព | *1,525.9* |
| ១.៦. អនុកម្មវិធីទី ៦ ៖ កិច្ចគាំពារសុខុមាលភាពមនុស្សចាស់ | *195.9* |
| ១.៧. អនុកម្មវិធីទី ៧ ៖ កិច្ចគាំពារអតីតយុទ្ធជន និងការគ្រប់គ្រងសកម្មភាពផ្តល់សេវាសុខុមាលភាពសង្គម | *4,187.2* |
| ១.៨. អនុកម្មវិធីទី ៨ ៖ សេវាគាំទ្រសេវាសុខុមាលភាពសង្គមដោយរាជធានី ខេត្ត | *19,841.4* |
| **២. កម្មវិធីទី ២ ÷ ពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ** | **1,156,747.5** |
| ២.១. អនុកម្មវិធីទី ១ ៖ អភិវឌ្ឍន៍របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល | *484,373.0* |
| ២.២. អនុកម្មវិធីទី ២ ៖ ការផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន | *662,712.5* |
| ២.៣. អនុកម្មវិធីទី ៣ ៖ ស្តារលទ្ធភាពពលកម្មកាយសម្បទា និងការគាំទ្រមុខរបរជនពិការ | *9,662.0* |
| **៣. កម្មវិធីទី ៣ ÷ ការគ្រប់គ្រងស្ថាប័ន និងកិច្ចការរដ្ឋបាលទូទៅ** | **60,512.6** |
| ៣.១. អនុកម្មវិធីទី ១ ៖ ការពង្រឹងសមត្ថភាពស្ថាប័ន និងកិច្ចសហការភាពជាដៃគូ | *28,063.9* |
| ៣.២. អនុកម្មវិធីទី ២ ៖ អភិវឌ្ឍភាពធនធានមនុស្ស | *361.1* |
| ៣.៣.អនុកម្មវិធីទី ៣ ៖ សេវាគាំទ្រការគ្រប់គ្រងស្ថាប័ន និងកិច្ចការរដ្ឋបាលទូទៅ ដោយរាជធានី ខេត្ត | *32,087.6* |

| តារាង ៤ ÷ តម្រោងចំណាយថវិកាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| សរុបរួម | **264,357.0** |
| **១. កម្មវិធីទី ១ ÷ ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ** | **28,993.7** |
| ១.១ អនុកម្មវិធីទី ១ ៖ លើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង | *6,989.4* |
| ១.២ អនុកម្មវិធីទី ២ ៖ ពង្រឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ | *0.0* |
| ១.៣ អនុកម្មវិធីទី ៣ ៖ ទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ | *1,180.0* |
| ១.៤ អនុកម្មវិធីទី ៤ ៖ យន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត | *800.0* |
| ១.៥ អនុកម្មវិធីទី ៥ ៖ ភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ | *18,629.9* |
| ១.៦.អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈរបស់មន្ទីរជំនាញរាជធានី ខេត្ត | *1,394.4* |
| **២. កម្មវិធីទី ២ ÷ ទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** | **65,269.6** |
| ២.១ អនុកម្មវិធីទី ១ ៖ គុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | *46,110.9* |
| ២.២ អនុកម្មវិធីទី ២ ៖ ការបណ្តុះបណ្តាលជំនាញដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម | *18,047.0* |
| ២.៣ អនុកម្មវិធីទី ៣ ៖ ភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដៃគូនានា | *117.4* |
| ២.៤ អនុកម្មវិធីទី ៤ ៖ ប្រព័ន្ធអភិបាលកិច្ចវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | *576.5* |
| ២.៥ អនុកម្មវិធីទី ៥ ៖ ជំរុញការស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យាអនុវត្តន៍ | *120.5* |
| ២.៦ អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់មន្ទីរជំនាញរាជធានី ខេត្ត | 297.3 |
| **៣. កម្មវិធីទី ៣ ÷ បរិយាកាសមុខរបរ និងការងារកាន់តែទូលំទូលាយ** | **3,896.5** |
| ៣.១ អនុកម្មវិធីទី ១ ៖ បង្កើនឱកាសការងារសមរម្យ និងផលិតភាពការងារខ្ពស់ | *23.1* |
| ៣.២ អនុកម្មវិធីទី ២ ៖ ការពង្រីកយន្តការ វិសាលភាព និងប្រសិទ្ធភាពការផ្តល់សេវាមុខរបរ និងការងារឱ្យឆ្លើយតបកាន់តែប្រសើរតាមតម្រូវការអ្នកប្រើប្រាស់សេវា | *1,632.8* |
| ៣.៣ អនុកម្មវិធីទី ៣ ៖ ពង្រឹងយន្តការវេទិកាការងារ និងបង្កើនការប្រមូលផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មានទីផ្សារការងារ | *1,597.2* |
| ៣.៤ អនុកម្មវិធីទី ៤ ៖ ពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស និងការពារពលករទេសន្តរប្រវេសន៍ខ្មែរ | *73.4* |
| ៣.៥ អនុកម្មវិធីទី ៥ ៖ បង្កើនផលិតភាពកម្លាំងពលកម្មដែលកំពុងស្ថិតក្នុងទីផ្សារការងារ | *570.0* |
| **៥. កម្មវិធីទី ៥ ÷ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | **166,197.2** |
| ៥.១ អនុកម្មវិធីទី ១ ៖ ការងាររដ្ឋបាល វិមជ្ឈការ វិសហមជ្ឈការ និងសេវាសាធារណៈ | *68,034.2* |
| ៥.២ អនុកម្មវិធីទី ២ ៖ ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន | *36,501.6* |
| ៥.៣ អនុកម្មវិធីទី ៣ ៖ អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ផែនការ ស្ថិតិ និងកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | *2,272.1* |
| ៥.៤ អនុកម្មវិធីទី ៤ ៖ កិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ សមភាពយេនឌ័រ និងសេវាសង្គម | *3,889.9* |
| ៥.៥.អនុកម្មវិធីទី ៥ ៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការសកម្មភាពរបស់ក្រសួង និងគោលនយោបាយពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 165.1 |
| ៥.៦ អនុកម្មវិធីទី ៦ ៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅរបស់មន្ទីរជំនាញរាជធានី ខេត្ត | *55,334.3* |

| តារាង ៥ ÷ គម្រោងចំណាយថវិកាក្រសួងបរិស្ថាន តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| **សរុបរួម** | **85,498.0** |
| **១. កម្មវិធីទី ១ ÷ កិច្ចគាំពារបរិស្ថាន** | **2,019.9** |
| ១.១. អនុកម្មវិធីទី ១ ៖ ការត្រួតពិនិត្យតាមដានគុណភាពបរិស្ថាន (គុណភាពទឹក-ដី-ខ្យល់) | *73.5* |
| ១.២. អនុកម្មវិធីទី ២ ៖ ការត្រួតពិនិត្យការបំពុលបរិស្ថាន (ដោយសំណល់រឹង-រាវ ផ្សែង-សំឡេង-រំញ័រ) | *170.2* |
| ១.៣. អនុកម្មវិធីទី ៣ ៖ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | *199.6* |
| ១.៤. អនុកម្មវិធីទី ៤ ៖ សេវាគាំទ្រកិច្ចគាំពារបរិស្ថាន | *1,217.7* |
| ១.៥. អនុកម្មវិធីទី ៥ ៖ សេវាគាំទ្រកិច្ចគាំពារបរិស្ថាន របស់មន្ទីររាជធានី ខេត្ត | *358.9* |
| **២. កម្មវិធីទី ២ ÷ ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន** | **7,465.2** |
| ២.១. អនុកម្មវិធីទី១៖ សេវាគាំទ្រការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ | *1,656.5* |
| ២.២. អនុកម្មវិធីទី២៖ ការគ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិ | *1,970.1* |
| ២.៣. អនុកម្មវិធីទី៣៖ សេវាគាំទ្រការងារសហគមន៍មូលដ្ឋាន | *1,436.3* |
| ២.៤. អនុកម្មវិធីទី៤៖ ការអភិរក្សតំបន់បេតិកភណ្ឌ | *269.3* |
| ២.៥. អនុកម្មវិធីទី៥៖ ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងសហគមន៍មូលដ្ឋាន | *335.0* |
| ២.៦.អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន របស់មន្ទីររាជធានី ខេត្ត | *1,798.0* |
| **៣. កម្មវិធីទី ៣ ÷ ការគ្រប់គ្រងការអភិវឌ្ឍន៍ដោយចីរភាព** | **1,256.0** |
| ៣.១. អនុកម្មវិធីទី ១ ៖ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងលើកកម្ពស់ការអនុវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | *837.9* |
| ៣.២. អនុកម្មវិធីទី ២ ៖ ជំរុញការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | *92.0* |
| ៣.៣. អនុកម្មវិធីទី ៣ ៖ការអភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព | *304.4* |
| ៣.៤.អនុកម្មវិធីទី ៤ ៖ សេវាគាំទ្រការគ្រប់គ្រងការអភិវឌ្ឍដោយចីរភាព របស់មន្ទីររាជធានី ខេត្ត | *21.7* |
| **៤. កម្មវិធីទី ៤ ÷ ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានបរិស្ថាន** | **2,082.3** |
| ៤.១. អនុកម្មវិធីទី ១ ៖ លើកកម្ពស់ចំណេះដឹង និងមេត្រីភាពបរិស្ថាន | *314.8* |
| ៤.២. អនុកម្មវិធីទី ២៖ គ្រប់គ្រងទិន្នន័យភូមិសាស្ត្រ និងពត៌មានបរិស្ថាន | *674.8* |
| ៤.៣. អនុកម្មវិធីទី ៣ ៖ សេវាកម្មគាំទ្រការងារគ្រប់គ្រងចំណេះដឹង និងព័ត៌មានបរិស្ថាន | *720.9* |
| ៤.៤.អនុកម្មវិធីទី ៤ ៖ សេវាគាំទ្រការគ្រប់គ្រងចំណេះដឹង និងព័ត៌មានបរិស្ថាន របស់មន្ទីររាជធានី ខេត្ត | *371.8* |
| **៥. កម្មវិធីទី ៥ ÷ សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ** | **72,674.6** |
| ៥.១. អនុកម្មវិធីទី១៖ ការគ្រប់គ្រងការងាររដ្ឋបាល និងខុទ្ទកាល័យ | *511.5* |
| ៥.២. អនុកម្មវិធីទី២៖ ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស | *20,703.2* |
| ៥.៣. អនុកម្មវិធីទី៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | *10,045.8* |
| ៥.៤. អនុកម្មវិធីទី៤៖ ការងារផែនការ និងការងារសង្គមក្នុងវិស័យបរិស្ថាន | *569.5* |
| ៥.៥. អនុកម្មវិធីទី៥៖ ការងារអធិការកិច្ច និងសវនកម្មផ្ទៃក្នុង | *250.0* |
| ៥.៦.អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ របស់មន្ទីររាជធានី ខេត្ត | *40,594.6* |

| តារាង ៦ ÷ គម្រោង ចំណាយ ថវិកាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| សរុបរួម | **165,056.0** |
| **១. កម្មវិធីទី ១ ÷ កិច្ចគាំពារបេតិកភណ្ឌវប្បធម៌រូបី** | **1,829.8** |
| ១.១ អនុកម្មវិធីទី ១៖ ការបង្កើនកិច្ចអភិរក្សបេតិកភណ្ឌវប្បធម៌រូបី | 1,004.0 |
| ១.២អនុកម្មវិធីទី ២៖ ការលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌រូបី | 525.3 |
| ១.៣.អនុកម្មវិធីទី ៣៖ សេវាគាំទ្រកិច្ចគាំពារបេតិកភណ្ឌវប្បធម៌រូបី ថ្នាក់រាជធានី ខេត្ត | 300.5 |
| **២. កម្មវិធី២ ÷ ការលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី** | **3,142.2** |
| ២.១.អនុកម្មវិធីទី ១៖ ការពង្រឹងកិច្ចអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី | 510.0 |
| ២.២.អនុកម្មវិធីទី ២៖ ការលើកតម្លៃបេតិកភណ្ឌវប្បធម៌អរូបី | 2,163.1 |
| ២.៣.អនុកម្មវិធីទី ៣៖ សេវាគាំទ្រការលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី ថ្នាក់រាជធានី ខេត្ត | 469.1 |
| **៣. កម្មវិធីទី ៣ ÷ ការពង្រឹងសេវាគាំទ្រទូទៅ** | **160,084.0** |
| ៣.១.អនុកម្មវិធីទី ១៖ ការពង្រឹងអភិបាលកិច្ច | 54,223.0 |
| ៣.២.អនុកម្មវិធីទី ២៖ ការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យវប្បធម៌ (សាលាមធ្យមវិចិត្រសិល្បៈ) | 2,994.0 |
| ៣.៣.អនុកម្មវិធីទី ៣៖ ការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យវប្បធម៌ (សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ) | 2,051.3 |
| ៣.៤.អនុកម្មវិធីទី ៤៖ កិច្ចគាំពារនិងលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌ (អាជ្ញាធរជាតិសំបូរព្រៃគុក) | 3,010.2 |
| ៣.៥.អនុកម្មវិធីទី ៥៖ កិច្ចគាំពារនិងលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌ (អាជ្ញាធរជាតិព្រះវិហារ) | 8,079.6 |
| ៣.៦.អនុកម្មវិធីទី ៦៖ កិច្ចគាំពារនិងលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌ ( អាជ្ញាធរអប្សរា) | 60,674.0 |
| ៣.៧.អនុកម្មវិធីទី ៧៖ការពង្រឹងយន្តការការងាររបស់គណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក | 409.5 |
| ៣.៨.អនុកម្មវិធីទី ៨៖ការពង្រឹងយន្តការការងាររបស់គណៈកម្មការជាតិយូណេស្កូកម្ពុជា | 320.0 |
| ៣.៩.អនុកម្មវិធីទី ៩៖ សេវាគាំទ្រការងារវប្បធម៌ និងវិចិត្រសិល្បៈ ថ្នាក់រាជធានី ខេត្ត | 28,322.4 |

| តារាង ៧ ÷ គម្រោង ចំណាយ ថវិកាក្រសួងព័ត៌មាន តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| សរុបរួម | **80,558.0** |
| **១. កម្មវិធីទី ១ ÷ ការគ្រប់គ្រង និងអភិវឌ្ឍវិស័យព័ត៌មាន** | ***80,558.0*** |
| ១.១. អនុកម្មវិធីទី ១ ៖ កិច្ចការព័ត៌មាន និងសោតទស្សន៍ | 972.0 |
| ១.២. អនុកម្មវិធីទី ២ ៖ ការងារផ្សព្វផ្សាយរបស់ទូរទស្សន៍ជាតិកម្ពុជា | 1,802.0 |
| ១.៣. អនុកម្មវិធីទី ៣ ៖ ការងារផ្សព្វផ្សាយរបស់វិទ្យុជាតិកម្ពុជា | 1,072.0 |
| ១.៤. អនុកម្មវិធីទី ៤ ៖ ការងារផ្សព្វផ្សាយរបស់ទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP | 790.0 |
| ១.៥. អនុកម្មវិធីទី ៥ ៖ កិច្ចការរដ្ឋបាលទូទៅ | 50,535.0 |
| ១.៦. អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រលើកកម្ពស់វិស័យព័ត៌មាន របស់មន្ទីរជំនាញរាជធានី ខេត្ត | 25,387.0 |

| តារាង ៨ ÷ គម្រោង ចំណាយ ថវិកាក្រសួងកិច្ចការនារី តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| សរុបរួម | **44,538.0** |
| **១.កម្មវិធីទី ១ ÷ កែប្រែស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ស្ត្រី** | **5,787.5** |
| ១.១ អនុកម្មវិធីទី ១ ៖ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ | *194.3* |
| ១.២ អនុកម្មវិធីទី ២ ៖ លើកកម្ពស់ការអប់រំ និងសុខុមាលភាពសង្គម | *309.8* |
| ១.៣ អនុកម្មវិធីទី ៣ ៖ អភិវឌ្ឍន៍សេដ្ឋកិច្ចស្ត្រី និងគ្រួសារ | *3,793.3* |
| ១.៤ អនុកម្មវិធីទី ៤ ៖ ការលើកកម្ពស់សុខភាពរបស់ស្ត្រី និងកុមារ | *217.2* |
| ១.៥ អនុកម្មវិធីទី ៥ ៖ កែប្រែស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ស្ត្រី ថ្នាក់រាជធានី-ខេត្ត | *1,272.9* |
| **២.កម្មវិធីទី ២ ÷ កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី** | **1,566.6** |
| ២.១ អនុកម្មវិធីទី ១ ៖ ទប់ស្កាត់ការរំលោភបំពានលើស្ត្រី | *192.1* |
| ២.២ អនុកម្មវិធីទី ២ ៖ ពង្រឹងសមត្ថភាពមន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌ | *168.0* |
| ២.៣ អនុកម្មវិធីទី ៣ ៖ ទប់ស្កាត់គ្រឿងញៀន និងអំពើជួញដូរមនុស្ស | *382.9* |
| ២.៤ អនុកម្មវិធីទី ៤ ៖ ទប់ស្កាត់អំពើហិង្សាលើស្ត្រី | *201.4* |
| ២.៥ អនុកម្មវិធីទី ៥ ៖ លើកកម្ពស់កិច្ចការពារស្ត្រីពិការ | *169.3* |
| ២.៦.អនុកម្មវិធីទី ៦ ៖ កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី ថ្នាក់រាជធានី-ខេត្ត | *452.9* |
| **៣.កម្មវិធីទី ៣ ÷ ការបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយ ជាតិ និងតាមវិស័យ** | **2,801.2** |
| ៣.១ អនុកម្មវិធីទី ១ ៖ អភិវឌ្ឍន៍សមត្ថភាពស្តីពី ការបញ្ជ្រាបយេនឌ័រ | *167.2* |
| ៣.២ អនុកម្មវិធីទី ២ ៖ ផ្សព្វផ្សាយកម្មវិធីនារីរតនៈ | *705.9* |
| ៣.៣ អនុកម្មវិធីទី ៣ ៖ ការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (CEDAW) | *800.1* |
| ៣.៤ អនុកម្មវិធីទី ៤ ៖ ស្ត្រី និងការធ្វើសេចក្តីសម្រេច | *177.7* |
| ៣.៥ អនុកម្មវិធីទី ៥ ៖ ការបញ្ជ្រាបយេនឌ័រក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | *162.3* |
| ៣.៦ អនុកម្មវិធីទី ៦ ៖ លើកកម្ពស់សមភាពយេនឌ័រ ថ្នាក់រាជធានី-ខេត្ត | *788.0* |
| **៤.កម្មវិធីទី ៤ ÷ ការគ្រប់គ្រង និងការអភិវឌ្ឍស្ថាប័ន** | **34,382.7** |
| ៤.១ អនុកម្មវិធីទី ១ ៖ ការរៀបចំផែនការស្ថិតិ និងការត្រួតពិនិត្យវាយតម្លៃឆ្លើយតបនឹងយេនឌ័រ | *179.1* |
| ៤.២ អនុកម្មវិធីទី ២ ៖ ពង្រឹងការងារហិរញ្ញវត្ថុ សវនកម្មផ្ទៃក្នុង និងអធិការកិច្ច | *166.8* |
| ៤.៣ អនុកម្មវិធីទី ៣ ៖ កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសមភាពយេនឌ័រ | *171.5* |
| ៤.៤ អនុកម្មវិធីទី ៤ ៖ អភិវឌ្ឍន៍សមត្ថភាពលើការងារគ្រប់គ្រងរដ្ឋបាល | *242.6* |
| ៤.៥ អនុកម្មវិធីទី ៥ ៖ សេវាគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ | *10,554.5* |
| ៤.៦ អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ ថ្នាក់រាជធានី-ខេត្ត | *23,068.2* |

| តារាង ៩ ÷ គម្រោង ចំណាយថវិកាក្រសួងធម្មការ និងសាសនា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| សរុបរួម | **66,270.0** |
| **១. កម្មវិធីទី ១ ÷ សុខដុមនីយកម្មសាសនានៅកម្ពុជា** | **66,270.0** |
| ១.១. អនុកម្មវិធីទី ១ ÷ ការអប់រំវិស័យពុទ្ធិកសិក្សា | *5,603.9* |
| ១.២. អនុកម្មវិធីទី ២ ÷ ការផ្សព្វផ្សាយព្រះពុទ្ធសាសនា និងរក្សាសុខដុមនីយកម្មខាងជំនឿសាសនា | *1,949.2* |
| ១.៣. អនុកម្មវិធីទី ៣ ÷ កិច្ចការរដ្ឋបាលទូទៅ | *18,095.9* |
| ១.៤. អនុកម្មវិធីទី ៤ ÷ សេវាគាំទ្រទូទៅរាជធានី ខេត្ត | *40,621.0* |

| តារាង ១០ ÷ គម្រោងចំណាយថវិកាក្រសួងទេសចរណ៍ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| សរុបរួម | **84,175.0** |
| **១.កម្មវិធីទី១៖ ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍** | **5,218.7** |
| ១.១. អនុកម្មវិធីទី១៖ ពង្រឹងគុណភាពឧស្សាហកម្មនិងសេវាកម្មទេសចរណ៍ "សេវាមួយស្តង់ដារមួយ" | 989.2 |
| ១.២. អនុកម្មវិធីទី២៖ ការបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ "បុគ្គលិកមួយ ជំនាញមួយ" | 989.5 |
| ១.៣. អនុកម្មវិធីទី៣៖ ជំរុញទេសចរណ៍ក្នុងស្រុក និងការយល់ដឹងសាធារណៈ | 658.0 |
| ១.៤. អនុកម្មវិធីទី៤៖ ជំរុញចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" | 1,530.0 |
| ១.៥. អនុកម្មវិធីទី៥៖ ពង្រឹងការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍និងការប្រឡងប្រណាំងនៅរាជធានី-ខេត្ត | 1,052.0 |
| **២.កម្មវិធីទី២៖ ការអភិវឌ្ឍទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ** | **13,374.5** |
| ២.១. អនុកម្មវិធីទី១៖ ផែនការ ការអភិវឌ្ឍផលិតផល និងវិនិយោគទេសចរណ៍ | 3,815.4 |
| ២.២. អនុកម្មវិធីទី២៖ ពង្រឹងនិងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការទេសចរណ៍ | 2,034.9 |
| ២.៣. អនុកម្មវិធីទី៣៖ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេស | 5,885.0 |
| ២.៤. អនុកម្មវិធីទី៤៖ ពង្រឹងគុណភាពប្រព័ន្ធស្ថិតិទេសចរណ៍ និងការសិក្សាស្រាវជ្រាវរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងការគ្រប់គ្រងស្ថិតិទេសចរណ៍ | 260.2 |
| ២.៥. អនុកម្មវិធីទី៥៖ ផែនការ ការអភិវឌ្ឍផលិតផល និងវិនិយោគទេសចរណ៍ រាជធានី-ខេត្ត | 1,379.0 |
| **៣.កម្មវិធីទី៣៖ សេវាគាំទ្រដំណើរការទូទៅរបស់ស្ថាប័ន** | **65,581.8** |
| ៣.១. អនុកម្មវិធីទី១៖ សេវារដ្ឋបាលសាធារណៈ ការសម្រួលការធ្វើដំណើរការ ដកជញ្ជូនតាមច្រកទ្វារ និងសន្តិសុខ សុវត្ថិភាពទេសចរ | 381.2 |
| ៣.២. អនុកម្មវិធីទី២៖ ការគ្រប់គ្រងនិងអភិវឌ្ឍន៍សមត្ថភាពមន្ត្រី | 16,911.4 |
| ៣.៣. អនុកម្មវិធីទី៣៖ ការគ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុ | 6,164.2 |
| ៣.៤. អនុកម្មវិធីទី៤៖ ការកសាង និងអនុវត្តបទដ្ឋានគតិយុត្តិ ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច | 434.7 |
| ៣.៥. អនុកម្មវិធីទី៥៖ កិច្ចការសម្របសម្រួលអន្តរវិស័យ | 308.3 |
| ៣.៦. អនុកម្មវិធីទី៦៖ ការគ្រប់គ្រងការប្រមូលចំណូលពីរមណីយដ្ឋានអង្គរ | 20,589.0 |
| ៣.៧. អនុកម្មវិធីទី៧៖ កិច្ចការគាំទ្រទេសចរណ៍រាជធានី-ខេត្ត | 20,793.0 |

| តារាង ១១ ÷ គម្រោង ចំណាយថវិកាក្រសួងធនធានទឹក និងឧតុនិយម តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| **សរុបរួម** | **158,619.0** |
| **១.កម្មវិធីទី១៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក** | **94,000.8** |
| ១.១. អនុកម្មវិធីទី១៖ កិច្ចដំណើរការ និងការជួសជុលថែទាំប្រព័ន្ធធារាសាស្ត្រ (ន.ធារាសាស្ត្រកសិកម្ម) | 74,067.9 |
| ១.២. អនុកម្មវិធីទី២៖ ស្តារ ជួសជុល និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ (ន.វិស្វកម្ម) | 77.0 |
| ១.៣. អនុកម្មវិធីទី៣៖ ការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក (ន.សហគមន៍កសិករប្រើប្រាស់ទឹក) | 43.4 |
| ១.៤. អនុកម្មវិធីទី៤៖ ការគ្រប់គ្រងសហគមន៍កសិករប្រើប្រាស់ទឹកប្រកបដោយនិរន្តរភាព (ន.សហគមន៍កសិករប្រើប្រាស់ទឹក) | 8,040.5 |
| ១.៥. អនុកម្មវិធីទី៥៖ ការលើកកម្ពស់ការយល់ដឹង ការផ្សព្វផ្សាយ រួមទាំងការសិក្សាស្រាវជ្រាវ ការរៀបចំ អនុវត្ត និងវាយតម្លៃសកម្មភាព និងគម្រោងពាក់ព័ន្ធ (គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា) | 620.0 |
| ១.៦. អនុកម្មវិធីទី៦៖ ការលើកកម្ពស់ប្រសិទ្ធភាពការងារសម្របសម្រួល និងការពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ (គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា) | 800.0 |
| ១.៧. អនុកម្មវិធីទី៧៖ សេវាគាំទ្រកិច្ចដំណើរការ ការជួសជុល និងថែទាំ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្ររបស់មន្ទីរជំនាញរាជធានី-ខេត្ត | 10,352.0 |
| **២.កម្មវិធីទី២៖ ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត** | **4,234.1** |
| ២.១. អនុកម្មវិធីទី១៖ ការងារអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវ និងទប់ទល់គ្រោះធម្មជាតិ (ន.ធារាសាស្ត្រកសិកម្ម) | 2,245.3 |
| ២.២. អនុកម្មវិធីទី២៖ សាងសង់ ជួសជុល និងថែទាំម៉ាស៊ីនបូមទឹកចល័ត និងស្ថានីយបូមទឹក (ន.ធារាសាស្ត្រកសិកម្ម) | 815.8 |
| ២.៣. អនុកម្មវិធីទី៣៖ ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត របស់មន្ទីរជំនាញរាជធានី-ខេត្ត | 1,173.0 |
| **៣.កម្មវិធីទី៣៖ ការការពារ និងអភិរក្សធនធានទឹក** | **2,283.8** |
| ៣.១. អនុកម្មវិធីទី១៖ ការគ្រប់គ្រងធនធានទឹកចំរុះ និងអាងទន្លេប្រកបដោយនិរន្តរភាព (ន.គ្រប់គ្រង និងអភិរក្សធនធានទឹក) | 83.8 |
| ៣.២. អនុកម្មវិធីទី២៖ សម្របសម្រួលការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបក្នុងស្មារតី ការការពារប្រព័ន្ធអេកូឡូស៊ីជីវចម្រុះនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ (អាជ្ញាធរទន្លេសាប) | 2,200.0 |
| **៤.កម្មវិធីទី៤៖ ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹក និងឧតុនិយម** | **2,297.6** |
| ៤.១. អនុកម្មវិធីទី១៖ រៀបចំចងក្រង គ្រប់គ្រងប្រព័ន្ធទិន្នន័យស្ថិតិរបស់ក្រសួង និងលើកផែនការអភិវឌ្ឍន៍ជាទូទៅរយៈពេល ខ្លី មធ្យម និងវែង លើគ្រប់ផ្នែកទាំងអស់របស់ក្រសួង និងតាមបណ្តាមន្ទីរធនធានទឹក និងឧតុនិយមរាជធានី-ខេត្ត (ន.ផែនការ និងសហប្រតិបត្តិការអន្តរជាតិ) | 74.4 |
| ៤.២. អនុកម្មវិធីទី២៖ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យជលសាស្ត្រ ការគ្រប់គ្រងច្រាំងទន្លេ និងការត្រួតពិនិត្យគុណភាពទឹក (ន.ជលសាស្ត្រ និងការងារទន្លេ) | 424.8 |
| ៤.៣. អនុកម្មវិធីទី៣៖ គ្រប់គ្រងព័ត៌មានឧតុនិយមប្រកបដោយប្រសិទ្ធភាព (ន.ឧតុនិយម) | 1,424.8 |
| ៤.៤. អនុកម្មវិធីទី៤៖ ការគ្រប់គ្រងធនធានទឹកក្រោមដី និងការសិក្សាស្រាវជ្រាវចងក្រងទិន្នន័យទឹកក្រោមដី (ន.ទឹកស្អាត និងអនាម័យ) | 259.6 |
| ៤.៥. អនុកម្មវិធីទី៥៖ គាំទ្រសេវាការគ្រប់គ្រងប្រព័ន្ធទិន្នន័យឧតុនិយម និងជលសាស្ត្ររបស់មន្ទីរជំនាញរាជធានី-ខេត្ត | 114.0 |

| តារាង ១១ ÷ គម្រោង ចំណាយ ថវិកាក្រសួងធនធានទឹក និងឧតុនិយម តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| **៥.កម្មវិធីទី៥៖ កិច្ចការរដ្ឋបាល ទូទៅ** | **55,802.7** |
| ៥.១. អនុកម្មវិធីទី១៖ ការកែលម្អការគ្រប់គ្រងរដ្ឋបាល និងការកសាងអភិវឌ្ឍន៍សមត្ថភាពមន្ត្រី (ន.រដ្ឋបាល និងធនធានមនុស្ស) | 571.0 |
| ៥.២. អនុកម្មវិធីទី២៖ ការរៀបចំផែនការគោលនយោបាយយុទ្ធសាស្ត្រ និងអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយម (ន.ផែនការ និងសហប្រតិបត្តិការអន្តរជាតិ) | 346.8 |
| ៥.៣. អនុកម្មវិធីទី៣៖ បង្កើនប្រសិទ្ធភាពការគ្រប់គ្រង និងការអនុវត្តថវិកា (ន.ហិរញ្ញវត្ថុ) | 22,344.6 |
| ៥.៤. អនុកម្មវិធីទី៤៖ ការអភិវឌ្ឍធនធានមនុស្សលើវិស័យធនធានទឹក (TSC) | 431.4 |
| ៥.៥. អនុកម្មវិធីទី៥៖ ធ្វើឱ្យប្រសើរឡើងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់សវនដ្ឋាន (ន.សវនកម្មផ្ទៃក្នុង) | 138.9 |
| ៥.៦. អនុកម្មវិធីទី៦៖ កិច្ចការរដ្ឋបាលទូទៅ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ (អាជ្ញាធរទន្លេសាប) | 2,100.0 |
| ៥.៧. អនុកម្មវិធីទី៧៖ ការពង្រឹងស្ថាប័ន និងអភិវឌ្ឍន៍ធនធានមនុស្សរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា) | 4,644.0 |
| ៥.៨. អនុកម្មវិធីទី៨៖ ពង្រឹងសេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងការកសាងសមត្ថភាពរបស់មន្ទីរជំនាញរាជធានី-ខេត្ត | 25,226.0 |

| តារាង ១២ ÷ គម្រោង ចំណាយ ថវិកាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
|---|---|
| **សរុបរួម** | **261,553.0** |
| **១.កម្មវិធីទី១៖ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច** | **34,207.1** |
| ១.១. អនុកម្មវិធីទី១៖ ការជំរុញអភិវឌ្ឍន៍ដំណាំស្រូវ | 3,620.6 |
| ១.២. អនុកម្មវិធីទី២៖ ការជំរុញអភិវឌ្ឍន៍សាកវប្បកម្ម | 5,077.3 |
| ១.៣. អនុកម្មវិធីទី៣៖ ការជំរុញអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម | 3,022.4 |
| ១.៤. អនុកម្មវិធីទី៤៖ ការពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព | 5,288.4 |
| ១.៥. អនុកម្មវិធីទី៥៖ ការជំរុញការអភិវឌ្ឍកៅស៊ូធម្មជាតិ | 1,359.8 |
| ១.៦. អនុកម្មវិធីទី៦៖ ការលើកកម្ពស់គុណភាពការងារពិសោធន៍និងស្រាវជ្រាវកៅស៊ូ | 2,836.0 |
| ១.៧. អនុកម្មវិធីទី៧៖ ការលើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម | 1,980.6 |
| ១.៨. អនុកម្មវិធីទី៨៖ ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្មប្រកបដោយចីរភាព | 4,368.0 |
| ១.៩. អនុកម្មវិធីទី៩៖ ការជំរុញផលិតកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច រាជធានី-ខេត្ត | 6,654.0 |
| **២.កម្មវិធីទី២៖ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ** | **15,883.1** |
| ២.១. អនុកម្មវិធីទី១៖ ការលើកកម្ពស់ផលិតកម្មសត្វ | 1,795.4 |
| ២.២. អនុកម្មវិធីទី២៖ ការលើកកម្ពស់សុខភាពសត្វ | 8,208.7 |
| ២.៣. អនុកម្មវិធីទី៣៖ ការពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព | 3,148.0 |
| ២.៤. អនុកម្មវិធីទី៤៖ ការជំរុញផលិតកម្មសត្វ និងសុខភាពសត្វ រាជធានី-ខេត្ត | 2,731.0 |
| **៣.កម្មវិធីទី៣៖ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម** | **17,519.9** |
| ៣.១. អនុកម្មវិធីទី១៖ ការគ្រប់គ្រង និងការអភិរក្សធនធានជលផល | 5,417.5 |
| ៣.២. អនុកម្មវិធីទី២៖ ការអភិវឌ្ឍវារីវប្បកម្ម និងខ្សែច្រវាក់តម្លៃជលផល | 2,322.2 |
| ៣.៣. អនុកម្មវិធីទី៣៖ ការពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព | 6,098.2 |
| ៣.៤. អនុកម្មវិធីទី៤៖ ការពង្រឹងការគ្រប់គ្រងធនធានជលផល និងការជំរុញវារីវប្បកម្ម រាជធានី-ខេត្ត | 3,682.0 |

| តារាង ១២ ÷ គម្រោង ចំណាយ ថវិកាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
| --- | --- |
| **៤.កម្មវិធីទី៤៖ ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ** | **14,564.2** |
| ៤.១. អនុកម្មវិធីទី១៖ ការគ្រប់គ្រងព្រៃឈើ | 1,834.6 |
| ៤.២. អនុកម្មវិធីទី២៖ ការអភិវឌ្ឍ និងស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ | 4,838.8 |
| ៤.៣. អនុកម្មវិធីទី៣៖ ការពង្រឹងការគ្រប់គ្រង និងសេវាគាំទ្រ | 3,604.8 |
| ៤.៤. អនុកម្មវិធីទី៤៖ ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ រាជធានី-ខេត្ត | 4,286.0 |
| **៥.កម្មវិធីទី៥៖ ការគ្រប់គ្រងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស** | **179,378.7** |
| ៥.១. អនុកម្មវិធីទី១៖ ការកសាងនិងការអនុវត្តផែនការគោលនយោបាយ និងវិនិយោគកសិកម្ម (នផក) | 1,731.9 |
| ៥.២. អនុកម្មវិធីទី២៖ ការរៀបចំ ការគ្រប់គ្រង និងការអនុវត្តថវិកា (នគហ) | 1,628.0 |
| ៥.៣. អនុកម្មវិធីទី៣៖ ការគ្រប់គ្រងស្ថាប័ននិងអភិវឌ្ឍន៍ធនធានមនុស្ស (នបុ.អកធ) | 73,093.7 |
| ៥.៤. អនុកម្មវិធីទី៤៖ ការជំរុញសវនកម្មផ្ទៃក្នុង (នសវក) | 312.4 |
| ៥.៥. អនុកម្មវិធីទី៥៖ កិច្ចការសហប្រតិបត្តិការអន្តរជាតិ (នសហ) | 3,292.5 |
| ៥.៦. អនុកម្មវិធីទី៦៖ ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម (ននក) | 379.7 |
| ៥.៧. អនុកម្មវិធីទី៧៖ ការងាររដ្ឋបាល និងការបញ្ជាបយេនឌ័រ (នាយកដ្ឋានកិច្ចការរដ្ឋបាល) | 4,742.0 |
| ៥.៨. អនុកម្មវិធីទី៨៖ កិច្ចការអធិការកិច្ច (អគ្គាធិការដ្ឋាន) | 275.1 |
| ៥.៩. អនុកម្មវិធីទី៩៖ ការគ្រប់គ្រងព័ត៌មាន ឯកសារ និងប្រព័ន្ធព័ត៌មានវិទ្យាកសិកម្ម (AIDOC) | 305.7 |
| ៥.១០. អនុកម្មវិធីទី១០៖ ការបណ្តុះបណ្តាលធនធានមនុស្សនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) | 4,627.0 |
| ៥.១១. អនុកម្មវិធីទី១១៖ ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនៅវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប | 4,094.0 |
| ៥.១២. អនុកម្មវិធីទី១២៖ ការបណ្តុះបណ្តាលធនធានមនុស្សនៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម | 3,650.0 |
| ៥.១៣. អនុកម្មវិធីទី១៣៖ ការងារផ្សព្វផ្សាយ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 1,323.7 |
| ៥.១៤. អនុកម្មវិធីទី១៤៖ សេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស រាជធានី-ខេត្ត | 79,923.0 |

| តារាង ១៣ ÷ គម្រោង ចំណាយ ថវិកាក្រសួងពាណិជ្ជកម្ម តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២១ |
| --- | --- |
| **សរុបរួម** | **123,743.0** |
| **១.កម្មវិធីទី១៖ ការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍន៍វិស័យឯកជន** | **13,279.0** |
| ១.១. អនុកម្មវិធីទី១៖ ពង្រឹងការគ្រប់គ្រង និងត្រួតពិនិត្យការផ្តល់អាជ្ញាប័ណ្ណ | 2,015.0 |
| ១.២. អនុកម្មវិធីទី២៖ ពិពិធកម្មទីផ្សារ និងការអភិវឌ្ឍផ្នែកឯកជន | 8,648.0 |
| ១.៣. អនុកម្មវិធីទី៣៖ ការផ្តល់សេវាសាធារណៈ ជំរុញពាណិជ្ជកម្ម និងការអភិវឌ្ឍផ្នែកឯកជន នៅមន្ទីរពាណិជ្ជកម្ម រាជធានី-ខេត្ត | 2,616.0 |
